**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាបញ្ចប់ការសិក្សា

# ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈ សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ករណីសិក្សា៖ អ្នករត់ម៉ូតូកង់បី(តុកតុក)ក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ហេង សារ៉ែន**

**ថោង យ៉ានីដា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ច៉ាន់ ស៊ុនដេត**



ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចលើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចចិត្តចាប់ដៃគូជាមួយគ្នាសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដើម្បីបន្សល់ទុកជាស្នាដៃមួយ សម្រាប់គុណប្រយោជន៍ដល់សិស្សនិស្សិតជំនាន់ក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្ត។

ដោយក្រុមយើងខ្ញុំសង្កេតឃើញថា ការប្រកបមុខរបររត់ម៉ូតូកង់បីនៅក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្នមានការកើនឡើងដែលគួរឲ្យកត់សម្គាល់ ហើយក៏ជាផ្នែកមួយនៃប្រភពចំណូលដ៏សំខាន់របស់គ្រួសារផងនោះ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទបញ្ចប់ការសិក្សាមួយនេះ យកមកសិក្សាស្រាវជ្រាវដែលទាក់ទងទៅនឹង **ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ**។ មូលហេតុដែលជំរុញឲ្យយើងខ្ញុំជ្រើសរើសយកប្រធានបទនេះក៏ព្រោះតែយើងខ្ញុំមានគោលបំណងចង់ពង្រីកចំណេះដឹង និងធ្វើការស្វែងយល់បន្ថែមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមនុស្សភាគច្រើនពុំធ្លាប់បានដឹងបានឮ។ តាមរយៈស្នាដៃស្រាវជ្រាវមួយនេះយើងខ្ញុំសង្ឃឹមថាវានឹងអាចជួយបន្ថែមនូវចំណេះដឹងថ្មីៗ និងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនទៅដល់អ្នកអានគ្រប់ៗរូបឲ្យបានយល់កាន់តែស៊ីជម្រៅអំពី សេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសារណាមួយក្បាលនេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជាពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងដោយអចេតនាណាមួយ ដែលមាននៅក្នុងសារណាមួយក្បាលនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលល្អឥតខ្ចោះនោះទេ។ ដូចនេះយើងខ្ញុំត្រូវទទួលស្គាល់នូវកំហុស និងទទួលយកនូវការកែតម្រូវតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីស្ថាបនារបស់មិត្ត និស្សិត និងអ្នកអានទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ហេង សារ៉ែន** និងនាងខ្ញុំឈ្មោះ **ថោង យ៉ានីដា** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ឆ្នាំសិក្សា២០១៩-២០២០នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីរនាក់សូមសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណចំពោះ**

- លោកឪពុក **ហេង សារឿន** និងអ្នកម្តាយ **ស ចន្ធី**
- លោកឪពុក **ញ៉ៀម សំអោក** និងអ្នកម្តាយ **នូវ ម៉ូរ៉ុំ**

ដែលលោកបានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់មើលថែរក្សាថ្នាក់ថ្នមរូបយើងខ្ញុំតាំងពីពេលចាប់កំណើត មកទល់សព្វថ្ងៃនេះពេញដោយក្តីស្រឡាញ់ ការសន្តោសប្រណី និងព្រហ្មវិហារធម៌ជាពិសេស លោកទាំងពីរតែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងទាំងស្មារតី និងសម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់ការសិក្សារៀនសូត្រដល់យើងខ្ញុំទាំងពីររូប។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** ជា **សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្រ្តាចារ្យ និង លោកស្រីសាស្រ្តាចារ្យទាំងអស់** ដែលបានខិតខំបង្ហាត់បង្រៀន ផ្ទេរចំណេះដឹងល្អៗយ៉ាងច្រើន ចំពោះនិស្សិត និងចំណាយពេលវេលា កម្លាំងកាយចិត្ត ដើម្បីបណ្តុះបណ្តាលយើងខ្ញុំ ដែលបានសិក្សាថ្នាក់បរិញ្ញាបត្រនៅទីនេះ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្រ្តាចារ្យ បណ្ឌិត **ខ៉ាន់ ស៊ុនដេត** ដែលបានខិតខំយកចិត្តទុកដាក់លះបង់នូវពេលវេលា ក្នុងការជួយណែនាំ និងកែសម្រួល ខ្លឹមសារ អក្ខរាវិរុទ្ធ ពោលគឺបានផ្តល់នូវគំនិតល្អៗ ផ្តល់នូវអនុសាសន៍ និងការកែតម្រូវយ៉ាងយកចិត្តទុកដាក់ចំពោះការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ ដែលជានិស្សិត។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ បងៗ ពូៗ និងអ៊ំៗ ដែលជាអ្នកប្រកបរបររត់ម៉ូតូកង់បី(តុកតុក) ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់ព័ត៌មានយ៉ាងក្បោះក្បាយដល់យើងខ្ញុំ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់លោកឪពុក អ្នកម្តាយ ព្រមទាំងឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោកសាស្រ្តាចារ្យណែនាំ ព្រមទាំងលោកលោកស្រី ជាសាស្រ្តាចារ្យ និងបុគ្គលិកទាំងអស់ សូមជួបប្រទះនូវព្រះពុទ្ធពរទាំងឡាយបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ៕

# មាតិកា

បញ្ជីអក្សរកាត់.....v
បញ្ជីតារាង.....vi
បញ្ជីក្រាហ្វិក.....vi

## សេចក្តីផ្តើម

១. លំនាំបញ្ហា.....១
២. ចំណោទបញ្ហា.....២
៣. គោលបំណងនៃការស្រាវជ្រាវ.....២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ.....៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.....៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ.....៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤

## ជំពូកទី១
## ទស្សនៈផ្សេងៗនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

១.១. និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....៥
១.២. លក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....៦
១.២.១. ប្រវត្តិនៃការសិក្សាទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....៦
១.២.២. ការកំណត់និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....៧
១.២.២.១. ទស្សនៈតាមបែបប្រពៃណី.....៧
១.២.២.២. ទស្សនៈតាមបែបថ្មី.....៨
១.២.២.៣. ការកំណត់និយមន័យដោយសកម្មភាព.....៨
១.២.៣. មូលហេតុនៃកំណើនសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....៩
១.២.៣.១. ការស្រូបយកកម្លាំងពលកម្មមានកំណត់.....៩
១.២.៣.២. ឧបសគ្គក្នុងការឈានចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ.....៩
១.២.៣.៣. កង្វះការយកចិត្តទុកដាក់ពីរដ្ឋាភិបាល.....១០
១.២.៣.៤. ភាពយ៉ាប់យ៉ឺននៃសេដ្ឋកិច្ច.....១១
១.២.៤. លក្ខណៈនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ.....១២

១.២.៤.១. ការងារស្របច្បាប់ និងការងារខុស ឬក្រៅច្បាប់ (Legal VS illegal work)... ១២
១.២.៤.២. លក្ខខណ្ឌពលកម្ម ឬការងារ (Conditions of Labour).................................. ១២
១.២.៤.៣. ប្រតិបត្តិការសាច់ប្រាក់ (Cash Transaction) ................................................ ១២
១.២.៤.៤. ប្រាក់ខែ ឬប្រាក់កម្រៃដែលគ្មានការចុះបញ្ជី................................................១៣
១.៣. ចំណុចវិជ្ជមាន និងអវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ............................................................១៣
១.៣.១. ចំណុចអវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ .................................................................... ១៤
១.៣.២. ចំណុចវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ...................................................................... ១៤
១.៤. ទំនាក់ទំនងរវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ............................................... ១៥
១.៤.១. ទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ......................... ១៦
១.៤.២. ទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងនិយោជិតក្រៅប្រព័ន្ធ ............................ ១៦
១.៥. ស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ........................................................................... ១៦
១.៥.១. ឋានៈការងាររបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ...................................................................... ១៦
១.៥.២. ក្រុមមនុស្សធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........................................................ ១៧
១.៥.៣. លក្ខណៈនៃអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ........................................................ ១៨
១.៥.៣.១. ការធ្វើចំណាកស្រុក.......................................................................................... ១៨
១.៥.៤. បញ្ហាប្រឈមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ .........................................................................១៩
១.៥.៤.១. ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ............................ ២០
១.៥.៤.២. បញ្ហាទាក់ទងនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ....................................................... ២០
១.៥.៥. សារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ...........................................................................២១

## ជំពូកទី២

## ស្ថានភាពអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ

២.១. ស្ថានភាពទូទៅក្នុងរាជធានីភ្នំពេញ..........................................................................................២៣
២.១.១. ទីតាំងភូមិសាស្ត្រ.......................................................................................................២៣
២.១.២. កំណើនប្រជាជន.........................................................................................................២៣
២.១.៣. ការកើនឡើងនៃយានយន្តក្នុងទីក្រុងភ្នំពេញ........................................................... ២៤
២.១.៤. គមនាគមន៍ផ្លូវគោកក្នុងរាជធានីភ្នំពេញ..................................................................... ២៥

២.១.៥. មធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ........ ២៦
២.២. ស្ថានភាពអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ ........ ២៧
២.២.១. កត្តាជំរុញឲ្យប្រកបមុខរបររត់ម៉ូតូកង់បី ........ ២៨
២.២.២. អត្ថប្រយោជន៍នៃការរត់ម៉ូតូកង់បី ........ ២៨
២.២.៣. បញ្ហាប្រឈមផ្សេងៗ ........ ២៩

## ជំពូកទី៣
## ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

៣.១. ការវិភាគបែបពិពណ៌នា ........ ៣១
៣.១.១. ស្ថានភាពទូទៅនៃអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ ........ ៣១
៣.១.១.១. ភេទ ........ ៣១
៣.១.១.២. អាយុ ........ ៣២
៣.១.១.៣. រយៈពេលប្រកបមុខរបរ ........ ៣៣
៣.១.១.៤. ស្ថានភាពគ្រួសារ ........ ៣៣
៣.១.១.៥. ចំនួនអ្នកនៅក្នុងបន្ទុក ........ ៣៤
៣.១.១.៦. កម្រិតវប្បធម៌ ........ ៣៥
៣.១.១.៧. ស្រុកកំណើត ........ ៣៦
៣.១.២. កត្តាជំរុញឲ្យប្រកបមុខរបររត់ម៉ូតូកង់បី ........ ៣៧
៣.១.៣. បញ្ហាប្រឈមនានាដែលអ្នករត់ម៉ូតូកង់បីជួបប្រទះ ........ ៣៩
៣.១.៤. ឥទ្ធិពលចំពោះគ្រួសារ ........ ៤១
៣.១.៥. ការលើកកម្ពស់ជីវភាពគ្រួសាររបស់អ្នករត់ម៉ូតូកង់បីតាមរយៈប្រាក់ចំណូល ........ ៤២
៣.១.៥.១. ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ ........ ៤២
៣.១.៥.២. ប្រាក់ចំណាយជាមធ្យមប្រចាំថ្ងៃ ........ ៤៤
៣.១.៥.៣. ប្រាក់សន្សំជាមធ្យមប្រចាំខែ ........ ៤៤
៣.២. ការវិភាគ SWOT ........ ៤៥
៣.២.១. ចំណុចខ្លាំង ........ ៤៦
៣.២.២. ចំណុចខ្សោយ ........ ៤៦

៣.២.៣. ឱកាស ........................................................................................................៤៦
៣.២.៤. ការគំរាមកំហែង..................................................................................................៤៦
៣.៣. លទ្ធផលស្រាវជ្រាវ ................................................................................................៤៦
**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**
១. សេចក្តីសន្និដ្ឋាន ......................................................................................................៤៨
២. អនុសាសន៍.............................................................................................................៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

## ពាក្យកាត់៖

| | | |
|---|---|---|
| ILO | International Labor Organization | អង្គការពលកម្មអន្តរជាតិ |
| MSMEs | Micro, Small & Medium-Size Enterprises | មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម |
| WIEGO | Women in Informal Employment: Globalizing and Organizing | ស្ត្រីនៅក្នុងការងារក្រៅប្រព័ន្ធ៖ ការធ្វើសាកលភាវូបនីយកម្ម និងការរៀបចំ |
| COVID-19 | Coronavirus Disease 2019 | ជំងឺកូវីដ១៩ |

## សញ្ញាសម្គាល់៖

| | |
|---|---|
| (%) | ភាគរយ |
| (.) | កាត់ខ្ទង់ពាន់ |
| (,) | ទសភាគ ឬក្បៀស |

# បញ្ជីតារាង

តារាងទី២.១៖ ស្ថិតិចំនួនយានយន្ត (ខែសីហា ២០០៦ ដល់ខែសីហា ២០១១)............................. ២៥
តារាងទី២.២៖ ប្រវែងបណ្ដាញផ្លូវរាជធានីភ្នំពេញ (គិតជាម៉ែត្រ)...................................................... ២៦
តារាងទី៣.១៖ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូកង់បី ................................................ ៤៣
តារាងទី៣.២៖ ប្រាក់ចំណាយជាមធ្យមប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូកង់បី ............................................... ៤៤
តារាងទី៣.៣៖ ប្រាក់សន្សំជាមធ្យមប្រចាំខែរបស់អ្នករត់ម៉ូតូកង់បី.................................................... ៤៥

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី៣.១៖ អាយុ........................................................................................................... ៣២
ក្រាហ្វិកទី៣.២៖ រយៈពេលប្រកបមុខរបររត់ម៉ូតូកង់បី ....................................................................... ៣៣
ក្រាហ្វិកទី៣.៣៖ ស្ថានភាពគ្រួសារ.......................................................................................... ៣៤
ក្រាហ្វិកទី៣.៤៖ ចំនួនសមាជិកក្នុងបន្ទុក.................................................................................. ៣៤
ក្រាហ្វិកទី៣.៥៖ អ្នករកចំណូលក្នុងគ្រួសារ................................................................................ ៣៥
ក្រាហ្វិកទី៣.៦៖ កម្រិតវប្បធម៌ ................................................................................................ ៣៦
ក្រាហ្វិកទី៣.៧៖ ស្រុកកំណើត................................................................................................ ៣៧
ក្រាហ្វិកទី៣.៨៖ កត្តាជំរុញក្នុងការប្រកបមុខរបររត់ម៉ូតូកង់បី .......................................................... ៣៧
ក្រាហ្វិកទី៣.៩៖ ប្រភពនៃដើមទុនសម្រាប់ចាប់ផ្ដើមអាជីវកម្ម.......................................................... ៣៨
ក្រាហ្វិកទី៣.១០៖ បញ្ហាប្រឈមពេលចាប់ផ្ដើមប្រកបមុខរបររត់ម៉ូតូកង់បី ........................................ ៣៩
ក្រាហ្វិកទី៣.១១៖ បញ្ហាប្រឈមពេលកំពុងប្រកបមុខរបររត់ម៉ូតូកង់បី ............................................. ៤០
ក្រាហ្វិកទី៣.១២៖ ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ........................................................................ ៤១
ក្រាហ្វិកទី៣.១៣៖ ឥទ្ធិពលវិជ្ជមានចំពោះគ្រួសារ .......................................................................... ៤២
ក្រាហ្វិកទី៣.១៤៖ ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ ...................................................................... ៤៣

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬក្រៅផ្លូវការ គឺជាផ្នែកមួយនៃសេដ្ឋកិច្ច ដែលមិនត្រូវបានយកពន្ធ និងមិនមានការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាលឡើយ ឬអាចនិយាយបានម្យ៉ាងទៀតថា សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសកម្មភាពសេដ្ឋកិច្ចចម្រុះ សហគ្រាស ការងារ និងកម្មករដែលមិនត្រូវបានកំណត់ដោយរដ្ឋ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាការងារដែលអាចរកបាននូវប្រាក់ចំណូលដើម្បីយកមកជួយផ្គត់ផ្គង់គ្រួសាររបស់ពួកគាត់បាន ដោយមិនចាំបាច់មានដើមទុនច្រើន ចំណេះដឹងខ្ពស់ ហើយជាពិសេស វាមានភាពងាយស្រួល និងមិនចាំបាច់ទៅចុះបញ្ជី។ ដោយសារតែកត្តាទាំងអស់នេះហើយ ដែលធ្វើឲ្យប្រជាជនមួយចំនួនធំនៅលើពិភពលោក បានឈានជើងចូលទៅប្រកបមុខរបររកស៊ីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមួយនេះ។ ជាពិសេស ប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ យោងតាមការចុះផ្សាយរបស់អង្គការពលកម្មអន្តរជាតិ(ILO) នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ក្នុងរបាយការណ៍មួយបានបង្ហាញថាប្រជាជនប្រមាណ២ពាន់លាននាក់ ដែលច្រើនជាង៦១% នៃប្រជាជននៅលើពិភពលោក គឺជាអ្នកប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ក្នុងរបាយការណ៍របស់ILOបានបញ្ជាក់ទៀតថា ៨៥,៨% នៃប្រជាជនអាហ្វ្រិក គឺជាអ្នកប្រកបមុខរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចំណែកឯ ៦៨,២%នៅអាស៊ីប៉ាស៊ីហ្វិក ៦៨,៦% នៅអារ៉ាប់ ៤០,០% នៅអាមេរិក និង ២៥,១% នៅអឺរ៉ុប និងអាស៊ីកណ្តាល។ ជាពិសេស ប្រជាជនដែលប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណជា៩៣% គឺស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[1] យោងតាមការចុះផ្សាយរបស់WIEGO បានឲ្យដឹងថា ប្រជាជននៅលើពិភពលោកប្រមាណ ៦១% គឺជាអ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬក្រៅផ្លូវការ។ ក្នុងនោះបុរសមានប្រមាណជា ៦៣% នៃបុរស ១០០% នៅលើពិភពលោក ចំណែកស្ត្រីមានត្រឹមតែប្រមាណ ៥៨% តែប៉ុណ្ណោះនៃស្ត្រី ១០០% នៅលើពិភពលោក ដែលកំពុងតែបម្រើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

## ១. លំនាំបញ្ហា

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅលើពិភពលោក តែងតែជួបនូវបញ្ហាភាពលើសនៃកម្លាំងពលកម្ម ដែលកម្លាំងពលកម្មទាំងអស់នោះកើតចេញពីកំណើនប្រជាជន និងភាពក្រីក្រដែលពួកគាត់គ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្រឲ្យបានដល់កម្រិតខ្ពស់ និងកង្វះដើមទុនជាដើម ដែលជាហេតុធ្វើឲ្យពួកគាត់ ពិបាកក្នុងការឈានជើងចូលប្រកួតប្រជែងក្នុងទីផ្សារ

[1] International Labor Organization, *Women and Men in the Informal Sector:* statistical picture (third edition) [ស្ត្រី និងបុរសនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ] (International Labour Office-Geneva: ILO, 2018), 13-14។

ការងារនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធជាមួយអ្នកដែលមានចំណេះដឹងខ្ពស់ និងដើមទុនច្រើន។ ទោះបីជាយ៉ាងនេះក្តីក៏ពួកគាត់ទាំងនោះនៅតែអាចរកប្រាក់ចំណូលបានដដែល ដោយគាត់បានសម្រេចចិត្តធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលការងារក្នុងវិស័យមួយនេះ អាចជួយលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់បានមួយកម្រិតផងដែរ។

ជាក់ស្តែងនៅប្រទេសកម្ពុជា កាលដើមឡើយគេតែងតែគិតថា អ្នកដែលប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ តួយ៉ាងដូចជាអ្នករត់ម៉ូតូកង់បី(តុកតុក) ជាដើម រកមួយថ្ងៃសម្រាប់ចាយវាយមួយថ្ងៃ គឺមិនអាចជួយធ្វើឲ្យគ្រួសារមានកម្រិតជីវភាពប្រសើរជាងមុននោះទេ។ ប៉ុន្តែនាពេលបច្ចុប្បន្ន តាមការសង្កេតជាក់ស្តែងបង្ហាញថាអ្នករត់ម៉ូតូកង់បីអាចរកប្រាក់ចំណូលបានគួរឲ្យកត់សម្គាល់ ដែលជាហេតុធ្វើឲ្យមានអ្នកប្រកបមុខរបរនេះជាច្រើននៅក្នុងរាជធានីភ្នំពេញ ដែលពួកគាត់អាចចូលរួមចំណែកក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់បាន។

## ២. ចំណោទបញ្ហា

ខណៈពេលដែលប្រទេសជាតិកំពុងមានការរីកចម្រើន ក៏មានការបង្កើតការងារជាច្រើនជូនប្រជាជន ដែលអ្នកខ្លះធ្វើការក្នុងវិស័យដូចជា វិស័យឧស្សាហកម្ម វិស័យកសិកម្ម និងវិស័យសេវាកម្មជាដើម ដើម្បីរកចំណូលជួយគ្រួសារ ទន្ទឹមនឹងនេះក៏មានអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធផងដែរ ពិសេសគឺអ្នករត់ម៉ូតូកង់បី ជាការងារមួយប្រភេទដែលកំពុងពេញនិយមនៅក្នុងរាជធានីភ្នំពេញ តើអ្នករត់ម៉ូតូកង់បី(តុកតុក) ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចជួយលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់បានយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងរាជធានីភ្នំពេញ ការកើនឡើងនៃអ្នករត់ម៉ូតូកង់បី គឺមានកំណើនគួរឲ្យកត់សម្គាល់ ដូច្នេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកមុខរបរមួយនេះ យកមកសិក្សាស្វែងយល់ដូចខាងក្រោម៖

- ស្វែងយល់ពីមូលហេតុក្នុងការសម្រេចចិត្តរបស់អ្នកប្រកបមុខរបររត់ម៉ូតូកង់បី(តុកតុក)
- ស្វែងយល់ពីផលប្រយោជន៍ដែលអ្នករត់ម៉ូតូកង់បីទទួលបានពីមុខរបរនេះ
- ស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់អ្នករត់ម៉ូតូកង់បី
- ស្វែងយល់ពីការគំរាមកំហែង និងផលលំបាករបស់អ្នករត់ម៉ូតូកង់បីក្នុងមុខរបរនេះ
- បង្ហាញការចូលរួមចំណែករបស់អ្នករត់ម៉ូតូកង់បី ក្នុងការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈប្រាក់ចំណូល និងសន្សំរបស់ពួកគាត់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះ យើងខ្ញុំនឹងសិក្សាទៅលើប្រាក់ចំណូលរបស់អ្នករត់ម៉ូតូកង់បី ដែលវាជាមុខរបរមួយប្រភេទ ក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅរាជធានីភ្នំពេញឆ្នាំ២០២០ ព្រមទាំងចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងផ្សេងៗ ដោយផ្តោតសំខាន់ទៅលើទិន្នន័យជាចម្បង ដែលទទួលបានពីកម្រងសំណួរទាំងស្រុង។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺពឹងផ្អែកទាំងស្រុងទៅលើទិន្នន័យជាចម្បង ដោយយើងខ្ញុំនឹងធ្វើការសម្ភាសន៍ជាមួយអ្នករត់ម៉ូតូកង់បី(តុកតុក) ដើម្បីទទួលយកព័ត៌មាន និងទិន្នន័យដែលយើងខ្ញុំចង់បាន ដោយប្រើប្រាស់នូវកម្រងសំណួរដែលយើងខ្ញុំបានរៀបចំ។ ទិន្នន័យនេះនឹងផ្តោតសំខាន់ទៅលើប្រាក់ចំណូល ចំណាយ សន្សំ របស់ពួកគាត់ថាតើប្រាក់ចំណូលរបស់ពួកគាត់អាចចូលរួមចំណែកក្នុងគ្រួសារបានឬយ៉ាងណា? ទិន្នន័យដែលត្រូវយកមកវិភាគ ពឹងផ្អែកទាំងស្រុងលើទិន្នន័យក្នុងកម្រងសំណួរ។

ដោយសារតែពេលវេលាដែលត្រូវធ្វើការស្រាវជ្រាវមានរយៈពេលខ្លី គួបផ្សំនឹងធនធានថវិកាដែលចំណាយមានកម្រិត យើងខ្ញុំសម្រេចជ្រើសរើសយកគំរូតាង (អ្នកត្រូវបានសម្ភាសន៍ គឺជាអ្នករត់ម៉ូតូកង់បីនៅក្នុងរាជធានីភ្នំពេញ) ចំនួនត្រឹមតែ ២០០នាក់ ដែលគំរូតាងទាំងនោះត្រូវបានជ្រើសរើសដោយចៃដន្យក្នុងចំណោមអ្នករត់ម៉ូតូកង់បីទាំងអស់ក្នុងរាជធានីភ្នំពេញ។ ការប្រមូលទិន្នន័យគិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។

ក្រោយពីទទួលបានទិន្នន័យ យើងខ្ញុំធ្វើការបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគទៅតាមអ្វីដែលយើងខ្ញុំចង់បាន។ ទិន្នន័យទាំងអស់ដែលទទួលបានពីការវិភាគក៏ត្រូវបានប្រើប្រាស់ដើម្បីជាមធ្យោបាយក្នុងការវិភាគ SWOT ផងដែរ។

ក្រៅពីទិន្នន័យចម្បង ក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវផ្សេងៗទៀតដូចជា ឯកសាររបាយការណ៍ចុះផ្សាយដោយអង្គការ ឬស្ថាប័នមួយចំនួនដូចជា អង្គការពលកម្មអន្តរជាតិ(ILO) វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងការស្រាវជ្រាវឯកសារតាមរយៈគេហទំព័រ(Website) ដើម្បីទទួលបានទិន្នន័យដែលមានស្រាប់មួយចំនួនទៅតាមតម្រូវការក្នុងការសរសេរ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្តល់នូវចំណេះដឹងជាច្រើនទាក់ទងទៅនឹងអ្នករត់ម៉ូតូកង់បី(តុកតុក) ដែលជាការងារមួយប្រភេទនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬក្រៅផ្លូវការបានចូលរួមចំណែកក្នុងការ

លើកកម្ពស់ជីវភាពគ្រួសារ ក៏ដូចជាបង្ហាញឲ្យឃើញពីផលលំបាកដែលពួកគាត់ជួបប្រទះក្នុងការចាប់ផ្ដើម និងកំឡុងពេលប្រកបមុខរបរនេះ។ ការសិក្សានេះនឹងក្លាយជាទុនមួយសម្រាប់អ្នកសិក្សាដែលមានចំណាប់អារម្មណ៍ ចង់យល់ ចង់ដឹង អំពីការចូលរួមក្នុងការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ ម្យ៉ាងវិញទៀត វាក៏អាចជាស្ពានចម្លងឲ្យអ្នកស្រាវជ្រាវដទៃទៀតធ្វើការសិក្សាស្រាវជ្រាវលើបញ្ហានេះបន្ថែមទៀតទៅតាមការចង់បាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជាបីជំពូកដែលមានដូចខាងក្រោម៖

ជំពូកទី១៖ យើងនឹងសិក្សាទៅលើនិយមន័យ លក្ខណៈទូទៅ ចំណុចវិជ្ជមាន-អវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា។

ជំពូកទី២៖ យើងនឹងបង្ហាញនូវស្ថានភាពទូទៅក្នុងរាជធានីភ្នំពេញដូចជា ទីតាំងភូមិសាស្ត្រ កំណើនប្រជាជន ការកើនឡើងនៃយានយន្ត គមនាគមន៍ផ្លូវគោក និងមធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ព្រមទាំងស្ថានភាពរបស់អ្នករត់ម៉ូតូកង់បីមានទាំងកត្តាជំរុញ អត្ថប្រយោជន៍ និងបញ្ហាប្រឈមផ្សេងៗ។

ជំពូកទី៣៖ វិភាគលើទិន្នន័យស្ថិតិដែលទទួលបានពីកម្រង់សំណួរ វិភាគតាមបែបSWOT និងលទ្ធផលស្រាវជ្រាវ។

# ជំពូកទី១
# ទស្សនៈផ្សេងៗនៃ
# សេដ្ឋកិច្ចក្រៅប្រព័ន្ធ

# ជំពូកទី១

# ទស្សនៈផ្សេងៗនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

យោងតាមប្រធានបទ "ការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ" ក្រុមយើងខ្ញុំនឹងលើកយកមកសិក្សាពន្យល់អំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងជំពូកនេះថាតើសេដ្ឋកិច្ចក្រៅប្រព័ន្ធមានប្រវត្តិមកពីណា និងមានលក្ខណៈដូចម្តេច? ហើយសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះសំដៅទៅលើអ្វី និងមានអត្ថន័យយ៉ាងណា? ដោយសារតែបច្ចុប្បន្ននេះ យើងសង្កេតឃើញថា អ្នកសិក្សាភាគច្រើនបានយកចិត្តទុកដាក់ និងស្រាវជ្រាវពាក់ព័ន្ធតែសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយពុំសូវបានចាប់អារម្មណ៍សិក្សាស្វែងយល់ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធប៉ុន្មានទេ ដែលជាហេតុធ្វើឲ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនសូវបានលើកយកមកពិភាក្សា ឬសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅនៅឡើយ។

## ១.១. និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចមួយប្រភេទ ដែលផ្ទុយពីសេដ្ឋកិច្ចក្នុងប្រព័ន្ធ ហើយត្រូវបានគេដាក់ឈ្មោះ និងហៅខុសៗគ្នាជាច្រើនដោយផ្អែកទៅតាមអ្នកប្រាជ្ញផ្សេងៗពីគ្នានៅលើពិភពលោក។ ក្នុងនោះយើងសង្កេតឃើញថាសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានគេដាក់ឈ្មោះដូចខាងក្រោម៖ សេដ្ឋកិច្ចមិនទៀងទាត់(Irregular Economy) សេដ្ឋកិច្ចរូងភ្នំ(Subterranean Economy) សេដ្ឋកិច្ចក្រោមដី(Underground Economy) សេដ្ឋកិច្ចខ្មៅ(Black Economy) សេដ្ឋកិច្ចស្រមោល (Shadow Economy) និងសេដ្ឋកិច្ចក្រៅផ្លូវការ(Informal Economy) ។[2]

លោក Gutmann ប្រើប្រាស់ពាក្យសេដ្ឋកិច្ចរូងភ្នំ (Subteranean economy) សំដៅលើប្រតិបត្តិការទាំងអស់ដែលគេចវេសន៍ពីការបង់ពន្ធ។[3]

លោក Feige បង្ហាញថា សេដ្ឋកិច្ចក្រៅប្រព័ន្ធជាសេដ្ឋកិច្ចលាក់បាំង(Hidden economy) ដោយសារតែវាគេចខ្លួនទាំងស្រុងពីការវាស់វែងរបស់សង្គម។[4]

លោក Tanzi (1982) ហៅសេដ្ឋកិច្ចក្រៅប្រព័ន្ធថាជាសេដ្ឋកិច្ចក្រោមដី(Underground economy) ព្រោះផលិតផលជាតិសរុបមិនត្រូវបានវាស់វែងដោយស្ថិតិផ្លូវការទាំងស្រុង។[5]

---

[2] Jan L. Losby, John F. Else, Marcia E. Kingslow, Elaine L. Edgcomb, Erika T. Malm និង Vivian Kao-Research Assistant, *Informal Economy Literature Review* (Washington, DC: The Aspen Institute, 2002), 2។

[3] ប៊ុន សេង និង អាន ស្រី, "ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ," (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច, ២០១៧), ៨។

[4] ដដែល។

[5] ដដែល។

យោងតាមប្រភពរបស់អង្គការពលកម្មអន្តរជាតិ(ILO) បានឲ្យដឹងថាសេដ្ឋកិច្ចក្រៅប្រព័ន្ធគឺសំដៅទៅលើអង្គភាព ដែលមានទំហំតូច ឬជាសហគ្រាសតាមបែបគ្រួសារដែលផលិត ចែកចាយទំនិញ ឬសេវាខ្នាតតូច ក្នុងនោះអ្នកផលិត គឺជាបុគ្គលឯករាជ្យ ស្វ័យគ្រប់គ្រងដែលមានអ្នកខ្លះបានជួលកម្មករនិយោជិតពីរបីនាក់ ឬបានប្រើប្រាស់កម្លាំងពលកម្មរបស់សមាជិកក្នុងបន្ទុកគ្រួសារផ្ទាល់សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ អង្គភាពទាំងនេះមានដំណើរការអាជីវកម្ម ដោយការចំណាយដើមទុនតិចតួច ព្រមជាមួយនឹងការប្រើប្រាស់នូវគ្រឿងបរិក្ខារបច្ចេកវិទ្យា និងជំនាញទាបក្នុងដំណើរការដែលជាហេតុធ្វើឲ្យទទួលបានផលិតផលទាប ព្រមទាំងមិនមានការត្រួតពិនិត្យស្តង់ដាគុណភាពផលិតផលផងដែរ។ ជាទូទៅ សេដ្ឋកិច្ចក្រៅប្រព័ន្ធសំដៅដល់សកម្មភាពទាំងឡាយណាដែលគ្មានរូបភាពជាក្រុមហ៊ុន និងគ្មានអាសយដ្ឋានទំនាក់ទំនងច្បាស់លាស់។ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសកម្មភាពទាំងឡាយណា ដែលបុគ្គលនោះធ្វើការងារដោយខ្លួនឯងជាធម្មតាគ្មានតួលេខនៅក្នុងស្ថិតិរបស់ជាតិឡើយ ជាពិសេស វាក៏ជាសកម្មភាព ដែលប្រើកម្លាំងពលកម្មច្រើនជាងប្រើម៉ាស៊ីន និងផ្លាស់ប្តូរកម្មករជាញឹកញាប់។ លើសពីនេះទៅទៀត សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសកម្មភាពទាំងឡាយណា ដែលប្រើប្រាស់កម្លាំងមនុស្ស ឬសត្វពាហនៈ និងជាសកម្មភាព ដែលកើតឡើងនៅស្ថានភាពគ្មានរចនាសម្ព័ន្ធត្រឹមត្រូវ គ្មានអាជ្ញាបណ្ណ ឬចុះបញ្ជីពាណិជ្ជកម្ម និងគ្មានការពាក់ព័ន្ធនឹងស្ថាប័នហិរញ្ញវត្ថុ ស្ថានប័នអប់រំបណ្តុះបណ្តាលផ្លូវការជាដើម។ ជាពិសេស វាគ្មានការរៀបចំឲ្យបានត្រឹមត្រូវ និងគ្មានការគាំទ្រ ព្រមទាំងគ្មានការគ្រប់គ្រងពីរដ្ឋាភិបាលទៀតផង ហើយរមែងដំណើរការនៅក្រៅក្របខណ្ឌច្បាប់ ដែលជាហេតុធ្វើឲ្យអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធពុំទទួលបានរបបសន្តិសុខសង្គម និងការធានារ៉ាប់រងផ្សេងៗ។[6]

## ១.២. លក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

### ១.២.១. ប្រវត្តិនៃការសិក្សាទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ពាក្យ សេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានបង្កើតឡើងនៅក្នុងការសិក្សារបស់អង្គការពលកម្មអន្តរជាតិ(ILO) លើទីផ្សារការងាររបស់ប្រទេសកាណា(Ghana)។ បន្ទាប់មក វាត្រូវបានប្រើនៅក្នុងរបាយការណ៍របស់ ILO ស្តីអំពីលក្ខខណ្ឌនៃទីផ្សារពលកម្មក្នុងប្រទេសនៅទ្វីបអាហ្វ្រិក និងត្រូវបានប្រើប្រាស់ ដោយធនាគារពិភពលោកក្នុងការសិក្សាពីនគរូបនីយកម្ម និងភាពក្រីក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ពាក្យនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ជាមធ្យោបាយក្នុងការពិពណ៌នា

[6] វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា, *ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា* (វិវេចនានិពន្ធ, បាងកក និងភ្នំពេញ៖ ការិយាល័យពលកម្មអន្តរជាតិ, ២០០៦), ១៤។

អំពីរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឬក្រៅផ្លូវការ ដែលប្រតិបត្តិការកើតឡើងក្រៅប្រព័ន្ធប្រពៃណី ហើយផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមយ៉ាងច្រើន។ វាត្រូវបាន វិវឌ្ឍន៍ ដោយគ្របដណ្តប់ទៅលើប្រភេទជាច្រើននៃប្រតិបត្តិការជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ទាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។[7]

### ១.២.២. ការកំណត់និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ពាក្យវិស័យបែបប្រពៃណី ឬវិស័យក្រៅប្រព័ន្ធ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជំនួសឲ្យពាក្យ "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដែលសំដៅទៅលើសកម្មភាពទាំងឡាយណា ដែលគ្មានការទទួលស្គាល់ ការកត់ត្រា ការការពារ ឬគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ច។ ស្របតាមសម័យកាល និងការវិវឌ្ឍន៍របស់ពិភពលោកបានធ្វើឲ្យ ILO បានបង្កើតពាក្យថ្មីមួយទៀតនោះគឺ "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" ដោយពង្រីកមកពីពាក្យ វិស័យក្រៅប្រព័ន្ធដើម្បីឲ្យស្របទៅតាមកាលៈទេសៈ នៃក្រុមអ្នកធ្វើការ និងសហគ្រាសទាំងនៅទីប្រជុំជន និងជនបទ ដែលធ្វើប្រតិបត្តិការក្រៅប្រព័ន្ធ។ លើសពីនេះទៀត រាជរដ្ឋាភិបាលមិនបានយកចិត្តទុកដាក់ និងគាំទ្រទៅលើសកម្មភាពនៃវិស័យក្រៅប្រព័ន្ធនោះទេ។ ការមិនយកចិត្តទុកដាក់ និងការមិនគាំទ្ររបស់រដ្ឋាភិបាលបែបនេះ ទើបធ្វើឲ្យការអភិវឌ្ឍសេដ្ឋកិច្ចទទួលបរាជ័យ ក្នុងការបង្កើតការងារឲ្យបានគ្រប់គ្រាន់ ដើម្បីស្រូបយកចំនួនកើនឡើងនៃនិកម្មជន(ជនគ្មានការងារធ្វើ)។ ដូច្នេះការកំណត់និយមន័យនៃពាក្យថា "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" ត្រូវបានកំណត់ដោយទស្សនៈពីរគឺ ទស្សនៈបែបប្រពៃណី និងទស្សនៈបែបថ្មី។

#### ១.២.២.១. ទស្សនៈតាមបែបប្រពៃណី

សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចបែបប្រពៃណី ដែលនឹងលិចបាត់នៅពេលដែលមានកំណើនឧស្សាហូបនីយកម្ម ហើយវាមិនផ្តល់ផលប្រយោជន៍ និងមិនមានការពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ចក្នុងប្រព័ន្ធឡើយ។ ទន្ទឹមនឹងនេះសេដ្ឋកិច្ចក្រៅប្រព័ន្ធ គ្រាន់តែជាកន្លែងបណ្តោះអាសន្នសម្រាប់ភាពលើសនៃកម្លាំងពលកម្មប៉ុណ្ណោះ នៅពេលដែលសេដ្ឋកិច្ចក្នុងប្រព័ន្ធមិនមានការរីកចម្រើន។ ការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានដូចជា អ្នករត់តាក់ស៊ី ពាណិជ្ជករនៅតាមដងផ្លូវ និងផលិតករដែលមានលក្ខណៈទ្រង់ទ្រាយតូច។ លើសពីនេះទៅទៀត សហគ្រិនក្នុងវិស័យនេះជាអ្នកស្ថិតនៅក្រៅច្បាប់ មិនបានចុះបញ្ជីសហគ្រាស មិនមានការគ្រប់គ្រង និងមិនបានបង់ពន្ធជូនរដ្ឋ។ ការងារទាំងអស់នេះគ្រាន់តែជាសកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតប៉ុណ្ណោះ ហើយការងារក្រៅ

[7] ដូច៣, ទំព័រ១០។

ប្រព័ន្ធមិនស្ថិតក្នុងគោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាលឡើយ។ ជាពិសេស បទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនមានសារៈសំខាន់ក្នុងការការពារសម្រាប់ការងារក្រៅប្រព័ន្ធនោះទេ។ ដូច្នេះ ការងារភាគច្រើនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានភាពទន់ខ្សោយ។

### ១.២.២.២. ទស្សនៈតាមបែបថ្មី

ការកំណត់និយមន័យនៃពាក្យ "សេដ្ឋកិច្ចក្រៅប្រព័ន្ធ" តាមទស្សនៈបែបថ្មី គឺត្រូវបានគេកំណត់ដោយផ្តោតសំខាន់ទៅលើសកម្មភាពការងារជាក់ស្តែង ដែលគេគិតថាជាការងារក្រៅប្រព័ន្ធ។ ការងារក្រៅប្រព័ន្ធមានដូចជា៖

❖ ការប្រកបមុខរបរដោយរកប្រាក់កម្រៃដោយខ្លួនឯង នៅក្នុងសហគ្រាសក្រៅប្រព័ន្ធគឺសំដៅដល់អ្នកធ្វើការមិនចុះបញ្ជី។ អ្នកទាំងនោះមានដូចជា និយោជិត អ្នកធ្វើប្រតិបត្តិការអាជីវកម្មដោយខ្លួនឯង និងអ្នកធ្វើការនៅក្នុងគ្រួសារមិនយកប្រាក់កម្រៃ។

❖ ការងារគិតម៉ោង នៅក្នុងការងារក្រៅប្រព័ន្ធរួមមាន និយោជិតនៃសហគ្រាសក្រៅប្រព័ន្ធ និងអ្នកធ្វើការទទួលប្រាក់ឈ្នួលតាមផ្ទះ អ្នកធ្វើការបណ្តោះអាសន្នជាដើម។

តាមការកំណត់និយមន័យតាមទស្សនៈបែបថ្មីនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានឲ្យដឹងថា សេដ្ឋកិច្ចក្រៅប្រព័ន្ធបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការងារជាច្រើន ការផ្តល់ទំនិញ និងសេវាសម្រាប់ក្រុមមនុស្ស ដែលជាអ្នករកបានប្រាក់ចំណូលទាប ឬជាអ្នកដែលរស់នៅស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រ ហើយថែមទាំងបានចូលរួមចំណែកដ៏សំខាន់ នៅក្នុងផលិតផលក្នុងស្រុកសរុបទៀតផង។ លើសពីនេះ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺមានទំនាក់ទំនងជាមួយនឹងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងផ្តល់នូវទំនិញ និងសេវាដល់សេដ្ឋកិច្ចក្នុងប្រព័ន្ធ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធបានឆ្លុះបញ្ចាំងនូវការជំនួសការស្រូបយកកម្លាំងពលកម្មនៃសហគ្រាសក្នុងប្រព័ន្ធ ដែលអសមត្ថភាព ហើយវាមិនគួរត្រូវបានគេគិតថាជា សេដ្ឋកិច្ចដែលស្ថិតនៅក្រៅច្បាប់នោះទេ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធរួមមាន សហគ្រាសក្រៅប្រព័ន្ធ ការងារក្រៅប្រព័ន្ធនិយោជិតនៃសហគ្រាសក្រៅប្រព័ន្ធ ពលករដែលរកបានប្រាក់កម្រៃសម្រាប់តែមួយថ្ងៃៗ និងអ្នកស៊ីឈ្នួលជាដើម។

### ១.២.២.៣. ការកំណត់និយមន័យដោយសកម្មភាព

ការកំណត់និយមន័យរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសកម្មភាព គឺផ្អែកទៅលើទស្សនៈតាមបែបបុរាណ។ សហគ្រាសមួយចំនួនត្រូវបានចាត់ទុកថាជាសហគ្រាសក្រៅប្រព័ន្ធ ព្រោះសហគ្រាសទាំងនោះ កម្រនឹងអនុលោមទៅតាមបទបញ្ញត្តិអាជីវកម្មដែលកំណត់ដោយរដ្ឋាភិបាល ដូចជាការបង់ពន្ធ លក្ខខណ្ឌការងារ និងការសុំអាជ្ញាបណ្ណធ្វើអាជីវកម្ម។ ទន្ទឹមនឹងនេះ សហគ្រាសក្រៅប្រព័ន្ធ មិនត្រឹមតែជាភ្នាក់ងារ ដែលស៊ីឈ្នួលពលកម្មប៉ុណ្ណោះទេ ថែមទាំងកាន់កាប់ និងធ្វើការ

ដោយខ្លួនឯងទៀតផង។ លើសពីនេះ ការប្រកបការងារដោយខ្លួនឯងរួមមាន អ្នកបើកបរតាក់ស៊ី អ្នកលក់ដូរតាមដងផ្លូវសាធារណៈ និងអ្នកយកផ្ទះខ្លួនឯងធ្វើអាជីវកម្មជាដើម។ ម្យ៉ាងវិញទៀត ការប្រកបរបររកស៊ីរបស់ពួកគាត់ កម្រនឹងប្រើប្រាស់ប្រព័ន្ធគណនេយ្យណាស់។

### ១.២.៣. មូលហេតុនៃកំណើនសេដ្ឋកិច្ចក្រៅប្រព័ន្ធ

#### ១.២.៣.១. ការស្រូបយកកម្លាំងពលកម្មមានកំណត់

នៅពេលដែលគេនិយាយពីកម្លាំងពលកម្ម ពិតណាស់គេនឹងនិយាយពីកំណើនប្រជាជននៅក្នុងប្រទេសមួយពីព្រោះប្រជាជន គឺជាកម្លាំងពលកម្មដ៏សំខាន់របស់ប្រទេសនីមួយៗ។ ជារៀងរាល់ឆ្នាំប្រជាជនច្រើនជាង ៧៥លាននាក់បានបូកបញ្ចូលបន្ថែមទៅក្នុងប្រជាជនលើ ពិភពលោក ហើយស្ទើរតែទាំងអស់នៃការកើនឡើងប្រជាជន៩៧% គឺនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[8]

ប្រជាជនស្ថិតនៅក្នុងកម្លាំងពលកម្ម គឺជាប្រជាជនស្ថិតនៅក្នុងកម្លាំងពលកម្មស្របច្បាប់ ប៉ុន្តែយោងតាមការធ្វើស្ថិតិក្នុងសកម្មភាពសេដ្ឋកិច្ច ប្រជាជនស្ថិតក្នុងកម្លាំងពលកម្មជាប្រជាជនដែលមានអាយុចាប់ពីអាយុអប្បបរមាដែលស្របច្បាប់បានកំណត់ឡើងទៅ។ ដើម្បីអនុគ្រោះដល់ការប្រៀបធៀបជាអន្តរជាតិ កម្លាំងពលកម្មស្របច្បាប់គឺចាប់ពីអាយុ ១៥ឆ្នាំឡើងទៅ ប៉ុន្តែកម្លាំងពលកម្មអប្បបរមាអាចខុសគ្នាពីប្រទេសមួយ ទៅប្រទេសមួយទៀតអាស្រ័យលើច្បាប់របស់ប្រទេសនីមួយៗ ហើយក៏មានប្រទេសជាច្រើនបានកំណត់អាយុ ៦៤ឆ្នាំជាកម្លាំងពលកម្ម អតិបរមាផងដែរ។

ការកើនឡើងបែបនេះហើយ ទើបធ្វើឲ្យមានការកើនឡើងនូវភាពលើសនៃកម្លាំងពលកម្មនៅក្នុងទីផ្សារពលកម្ម។ ការងារនៅក្នុងវិស័យក្នុងប្រព័ន្ធបានស្រូបយកកម្លាំងពលកម្មនៅមានកម្រិតនៅឡើយ។ ដូច្នេះកម្លាំងពលកម្មដែលនៅសល់ទំនេរគ្មានជម្រើសផ្សេងក្រៅពីទៅប្រកបមុខរបរនៅក្នុងវិស័យក្រៅប្រព័ន្ធនោះទេ ព្រោះមុខរបរប្រភេទនេះ ទោះបីមានដើមទុនតិច ការអប់រំទាប ឬគ្មានជំនាញយ៉ាងណាក៏ដោយក៏អាចប្រកបមុខរបរបានដែរ។

#### ១.២.៣.២. ឧបសគ្គក្នុងការឈានចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ

ការិយាធិបតេយ្យ និងអំពើពុករលួយមានការពាក់ព័ន្ធគ្នាយ៉ាងស្អិតរមួត ដែលបណ្តាលឲ្យថ្លៃនៃការប្រកបអាជីវកម្មគ្រប់ប្រភេទបានក្លាយជាឧបសគ្គមួយគួរឲ្យបារម្ភ។ ប្រតិបត្តិករអាជីវកម្មមិនមានការលើកទឹកចិត្ត ដើម្បីស្នើសុំឋានៈអាជីវកម្មចូលក្នុងប្រព័ន្ធ លុះត្រាតែអាជីវកម្មមានទំហំធំ

---

[8] Michael P. Todaro និង Stephen C. Smith, *Economic Development* [សេដ្ឋកិច្ចអភិវឌ្ឍន៍], បោះពុម្ពលើកទី១១ (Addison-Wesley, 2012), 270។

ដែលពួកគេមិនអាចគេចវេសន៍បាន។ ការចៀសវាងពីការិយាធិបតេយ្យដ៏ច្រើនលើសលប់របស់រដ្ឋាភិបាល គឺជាហេតុផលចាប់បង្ខំមួយដែលធ្វើឲ្យសហគ្រាសមួយចំនួនព្យាយាមស្ថិតនៅក្រៅប្រព័ន្ធ។

នីតិវិធីស្នើរសុំអាជ្ញាបណ្ណមានភាពសាំញ៉ាំ និងចំណាយខ្ពស់នៃការចុះបញ្ជី ធ្វើឲ្យមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម(MSMEs) ជាច្រើន ធ្វើការសន្និដ្ឋានថា ការចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ គឺមិនអាចធ្វើទៅបាន ដោយពួកគេបានលើកឡើងថាពួកគេត្រូវតែរក្សានូវលេខអត្តសញ្ញាណប័ណ្ណនៃពន្ធប៉ាតង់ និងពន្ធតម្លៃបន្ថែមដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវតែទទួលបានការអនុញ្ញាតយល់ព្រមទៅលើបទបញ្ជាផ្ទៃក្នុង នៃសហគ្រាសរបស់ខ្លួនពីសំណាក់ក្រសួងការងារ ម្យ៉ាងវិញទៀត ប្រសិនបើសកម្មភាពអាជីវកម្មដែលស្នើឡើងទាក់ទងនឹងផ្នែកជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងក្រសួងដទៃទៀត អាជ្ញាបណ្ណពីក្រសួងពាក់ព័ន្ធទាំងនោះត្រូវបានគេទាមទារឲ្យមានថែមទៀត ដើម្បីបំពេញឲ្យគ្រប់បែបបទចុះបញ្ជីពាណិជ្ជកម្ម។ មិនតែប៉ុណ្ណោះនៅតម្រូវឲ្យមានដើមទុនមួយចំនួនតម្កល់ទុកនៅក្នុងធនាគារជាតិ បូករួមជាមួយនឹងការចំណាយពេលវេលាច្រើនផង ហើយការចុះបញ្ជីជាទូទៅត្រូវចំណាយទាំងថ្លៃផ្លូវការ និងថ្លៃសម្របសម្រួលផង ទើបធ្វើឲ្យប្រជាជនត្រូវបង្ខំចិត្តនៅតែបន្តប្រកបមុខរបរស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

កត្តាទាំងនេះហើយ ដែលជាមូលហេតុធ្វើឲ្យប្រតិបត្តិករអាជីវកម្មយល់ថាការដែលនៅក្រៅប្រព័ន្ធមានភាពប្រសើរជាង យ៉ាងហោចណាស់ក៏អាចចៀសវាងការមកត្រួតពិនិត្យដោយអធិការកិច្ចជាផ្លូវការ និងក្រៅផ្លូវការ ចាប់ពីរដ្ឋអំណាចមូលដ្ឋាន ដល់រដ្ឋបាលកណ្តាលដែលស្វែងរកសំណូក។ ការគេចពន្ធ និងកង្វះការជឿទុកចិត្តលើតម្លាភាពរបស់រដ្ឋាភិបាលលើការគ្រប់គ្រងពន្ធគឺជាទឡ្ហីករណ៍ដ៏មានឥទ្ធិពលសម្រាប់ភាពក្រៅប្រព័ន្ធ។[៩]

### ១.២.៣.៣. កង្វះការយកចិត្តទុកដាក់ពីរដ្ឋាភិបាល

ការមិនយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល មកលើសេដ្ឋកិច្ចក្រៅប្រព័ន្ធបែបនេះហើយ ដែលវាជាមូលហេតុមួយផ្នែក ដែលបណ្តាលឲ្យមានការបង្កើតការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកាន់តែច្រើនឡើងៗជារៀងរាល់ឆ្នាំ។ ការងារដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានគេគិតថា ជាការងារបណ្តោះអាសន្នតែប៉ុណ្ណោះ។ វានឹងបាត់ទៅវិញដោយខ្លួនឯង នៅពេលណា

[៩] វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា, *ការងារសមរម្យក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា* (វិវេចនានិពន្ធ, បាងកក និងភ្នំពេញ៖ ការិយាល័យពលកម្មអន្តរជាតិ, ២០០៦), ១៩។

ដែលសេដ្ឋកិច្ចមានការរីកចម្រើន។ ដូច្នេះហើយទើបរាជរដ្ឋាភិបាលពុំមានវិធានការទប់ស្កាត់ ឬអន្តរាគមន៍ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធឡើយ។

### ១.២.៣.៤. ភាពយ៉ាប់យ៉ឺននៃសេដ្ឋកិច្ច

ខណៈពេលដែលសេដ្ឋកិច្ចនៅក្នុងប្រទេសមួយចំនួនមានការធ្លាក់ចុះ ប្រជាជនមួយភាគត្រូវបានបាត់បង់ការងារ ដែលជាប្រភពចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ប្រជាជនទាំងនោះមួយចំនួននឹងសម្រេចចិត្តធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទោះបីជាទទួលបាននូវប្រាក់កម្រៃទាប និងពុំទទួលបាននូវការការពារត្រឹមត្រូវក៏ដោយ ពីព្រោះពួកគាត់បានគិតថាទទួលបានប្រាក់ចំណូលទាប វាប្រសើរជាងមិនទទួលបានប្រាក់ចំណូល។ យោងតាមការចុះផ្សាយរបស់ILO ឆ្នាំ២០១៨ ស្តីពីទំហំការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធបានបង្ហាញថា ប្រជាជនចំនួន ២ពាន់លាននាក់ស្មើនឹង៦១% នៃកម្លាំងពលកម្មនៅលើពិភពលោកកំពុងបម្រើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។[10] ប្រសិនបើ ការងារមួយចំនួននៅតែបន្តបាត់បង់តាមរយៈការថយចុះនៃសេដ្ឋកិច្ច ព្រមជាមួយនឹងការវិលត្រឡប់នៃជនចំណាកស្រុកមកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធវិញ។ យ៉ាងណាមិញ ទោះបីជាកំណើនសេដ្ឋកិច្ចក្នុងប្រទេសមានការកើនឡើងក៏ដោយក៏កំណើន នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែមានការរីករាលដាលក្នុងតំបន់មួយចំនួននៃប្រទេសនោះដដែល ជាពិសេស គឺប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែង ទោះបីជាប្រទេសឥណ្ឌាមានកំណើនសេដ្ឋកិច្ចលើសពី ៥% ក្នុងកំឡុងទសវត្សរ៍ចុងក្រោយនេះ ក៏ដោយក៏គេសង្កេតឃើញថា ប្រជាជន ៩នាក់ក្នុងចំណោម ១០នាក់ ឬប្រហែលជា ៣៧០លាននាក់ ពុំមានការងារត្រឹមត្រូវក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។[11]

បញ្ហាខាងលើទាំងអស់នេះ គឺជាមូលហេតុដែលធ្វើឲ្យមានការកើនឡើងនូវសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារ ដល់ប្រជាពលរដ្ឋជាច្រើន ដែលអាចឲ្យប្រជាពលរដ្ឋបង្កើននូវប្រាក់ចំណូលរបស់ពួកគាត់បន្ថែមទៀត ជាពិសេសជួយក្នុងការកាត់បន្ថយការចំណាយមួយចំនួន ដល់ប្រជាពលរដ្ឋទៀតផង ដោយបានជួយបំពេញនូវសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់នូវទំនិញ និងសេវាក្នុងតម្លៃថោកសមរម្យ។

---

[10] International Labour Organization, *Wen and me in the informal economy: a statistical picture (third edition)* [ស្ត្រី និងបុរសនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ] (International Labour Office-Geneva: ILO, 2018), 1។

[11] ដូច៣, ទំព័រ១៦។

### **១.២.៤. លក្ខណៈនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**[12]

#### **១.២.៤.១. ការងារស្របច្បាប់ និងការងារខុស ឬក្រៅច្បាប់** (Legal VS illegal work)

សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាការងារមួយដែលមិនមានចែងក្នុងច្បាប់។ ជាទូទៅការងារដែលស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាការងារមួយដែលមានលក្ខណៈតូច អាចនិយាយបានថាគឺជាការដោះដូរទំនិញ ឬសេវាដែលមានលក្ខណៈជាកម្មសិទ្ធិឯកជន ទ្រង់ទ្រាយតូច ដើមទុនតិច មានភាពមិនច្បាស់លាស់ ទាំងទំហំការងារ ប្រាក់ចំណូល និងប្រាក់ចំណេញ ដូច្នេះហើយទើបមិនមានចែងក្នុងច្បាប់ ប៉ុន្តែរាល់សកម្មភាពការងារក្រៅប្រព័ន្ធ ត្រូវបានវែកញែក ឬកំណត់ថាស្របច្បាប់ ឬខុសច្បាប់ដោយផ្អែកលើទំនិញ ឬសេវា ផលិត ឬដោះដូរដែលត្រូវបានអនុញ្ញាត ឬហាមឃាត់ដោយច្បាប់។ ឧទាហរណ៍៖ ការលក់អាហារ សម្លៀកបំពាក់ ឬសេវាកម្មថែទាំក្មេង គឺជាទង្វើស្របច្បាប់ ប៉ុន្តែអាចកំណត់បានថាជាសកម្មភាពខុសច្បាប់នៅពេលដែលសកម្មភាពទាំងអស់នោះ មិនបានចុះបញ្ជីពាណិជ្ជកម្ម ឬគេចវេសន៍ពីពន្ធ។

#### **១.២.៤.២. លក្ខខណ្ឌពលកម្ម ឬការងារ** (Conditions of Labour)

ការងារដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺមិនត្រូវបានកំណត់ដោយច្បាប់នោះទេ ដូច្នេះហើយរាល់ប្រាក់ឈ្នួល ដែលទទួលបានពីការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺមិនមានការការពារពីច្បាប់ដូចការងារសេដ្ឋកិច្ចក្នុងប្រព័ន្ធឡើយ មិនមានការធានាសុវត្ថិភាពកន្លែងការងារ សុខភាពនិយោជិត ឬម៉ោងការងារនោះទេ រាល់សកម្មភាពទាំងអស់ គឺធ្វើឡើងដោយមានការព្រមព្រៀងរវាងភាគីកូនឈ្នួល(និយោជិត) និងថៅកែ(និយោជក) ដោយមិនមានលក្ខខណ្ឌការងារដូចមានក្នុងច្បាប់ការងារ ដែលរដ្ឋបានកំណត់។ ឧទាហរណ៍៖ អ្នកធ្វើការនឹងត្រូវបានផ្តល់ប្រាក់កម្រៃទាបជាងអ្នកធ្វើការធម្មតា ម្យ៉ាងវិញទៀត ប្រាក់កម្រៃទាំងនោះមិនបានរួមបញ្ចូលដូចជាប្រាក់របបសន្តិសុខសង្គម ប្រាក់ធានារ៉ាប់រងសុវត្ថិភាពជាដើម ដោយសារតែពួកគេធ្វើការងារពុំបានចុះបញ្ជីការងារត្រឹមត្រូវតាមបទបញ្ញត្តិការងារ។

#### **១.២.៤.៣. ប្រតិបត្តិការសាច់ប្រាក់** (Cash Transaction)

ការងារដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធភាគច្រើន គឺជាអាជីវកម្មខ្នាតតូចលក្ខណៈគ្រួសាររាល់ចំណូល និងចំណាយ ដែលទូទាត់សុទ្ធសឹងជាសាច់ប្រាក់ ដែលត្រូវយកមកដោះដូរទំនិញ ឬសេវាដែលរាប់ទាំងសកម្មភាពទាំងអស់នៃការដោះដូរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធភាគច្រើន

[12] Natasja VanderBerg, *The Informal Economy: A literature review* [សេដ្ឋកិច្ចក្រៅប្រព័ន្ធ៖ ការពិនិត្យអក្សរសាស្ត្រ] (2014), 7។

គឺត្រូវបានប្រើប្រាស់ជាសាច់ប្រាក់ផ្ទាល់ជាជាងការប្រើប្រាស់សែក(Check) ឬប័ណ្ណឥណទាន។ ជាពិសេស ការងារក្រៅប្រព័ន្ធ គឺប្រព្រឹត្តទៅនៅក្រៅច្បាប់កំណត់ ដែលមិនត្រូវបានកាត់ពន្ធ ឬបង់ពន្ធជូនរដ្ឋឡើយ។ បែបនេះហើយទើបធ្វើឲ្យរដ្ឋពិបាកក្នុងការកំណត់រាល់ការទូទាត់ចំណូល និងចំណាយរបស់អាជីវកម្មខ្នាតតូចប្រភេទនេះ ដោយសារតែមិនមានការទូទាត់នៅក្នុងគណនីធនាគារណាមួយ។ ចំណែកឯការងារដែលស្ថិតនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធភាគច្រើនត្រូវបានទូទាត់នៅក្នុងគណនីធនាគារ ដែលធ្វើឲ្យមានភាពងាយស្រួលដល់រដ្ឋក្នុងការកាត់ពន្ធ ព្រោះរដ្ឋអាចកំណត់នូវទំហំនៃប្រាក់ចំណូល ចំណាយ ឬប្រាក់ខែបុគ្គលិកបានដោយងាយ។

ម្យ៉ាងវិញទៀត ប្រតិបត្តិការខ្លះនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺផ្អែកទៅលើការផ្លាស់ប្តូរសេវាដែលត្រូវបានគេហៅថា ការទូទាត់តាមរយៈការដោះដូរអ្វីផ្សេង។ ឧទាហរណ៍៖ ជាងរថយន្តម្នាក់មិនបានគិតថ្លៃឈ្នួលជួសជុលរថយន្តពីជាងជួសជុលម៉ាស៊ីនត្រជាក់ទេ គឺគាត់បានថ្នូរនឹងការដែលជាងជួសជុលម៉ាស៊ីនត្រជាក់មកជួសជុលម៉ាស៊ីនត្រជាក់ដែលខូចក្នុងផ្ទះរបស់គាត់វិញ។ ការធ្វើបែបនេះ គឺដើម្បីបញ្ចៀសការកត់ត្រានូវប្រតិបត្តិការសាច់ប្រាក់។

#### **១.២.៤.៤. ប្រាក់ខែ ឬប្រាក់កម្រៃដែលគ្មានការចុះបញ្ជី**

នៅពេលដែលការទូទាត់សាច់ប្រាក់មិនត្រូវបានកត់ក្នុងប្រតិបត្តិការ ប្រាក់ចំណូល និងមិនត្រូវបានកាត់ពន្ធអាករ។ ការធ្វើបែបនេះ ផ្តល់ផលចំណេញទាំងសងខាងដល់និយោជក និងនិយោជិតនឹងមិនត្រូវបានកាត់ពន្ធ ខណៈពេលដែលនិយោជកមិនចាំបាច់រាយការណ៍ដល់ក្រសួងពាក់ព័ន្ធនូវចំនួននិយោជិតដែលខ្លួនជួលមកធ្វើការ។

## **១.៣. ចំណុចវិជ្ជមាន និងអវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**[13]

វិសាលភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធមានផលប៉ះពាល់ ដែលគួរឲ្យកត់សម្គាល់ទៅលើក្រុមមនុស្សផ្សេងៗគ្នា។ ផលប៉ះពាល់ធំបំផុត គឺទៅលើកម្មករ ឬនិយោជិត អ្នកធ្វើការឲ្យខ្លួនឯង នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លើសពីនេះទៅទៀត សេដ្ឋកិច្ចក្រៅប្រព័ន្ធបានជះឥទ្ធិពល លើនិយោជក និងអាជីវកម្មក្នុងស្រុក អ្នកប្រើប្រាស់និងអតិថិជន និងហេដ្ឋារចនាសម្ព័ន្ធការងារនិងសង្គមជាដើម។ ផលប៉ះពាល់នេះមានទាំងវិជ្ជមាន និងអវិជ្ជមាន។

[13] Natasja Vanderberg, *The Informal Economy: A literature review* [សេដ្ឋកិច្ចក្រៅប្រព័ន្ធ៖ ការពិនិត្យអក្សរសាស្ត្រ] (2014), 11-12។

### ១.៣.១. ចំណុចអវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**ក. សម្រាប់កម្មករ ឬពាណិជ្ជករក្រៅប្រព័ន្ធ** (For Informal Worker/Traders)

- កង្វះហិរញ្ញវត្ថុ
- ការទទួលបានប្រាក់ឈ្នួលមិនសមស្របទៅនឹងកម្លាំងពលកម្ម
- ពិបាកក្នុងការពង្រីកអាជីវកម្ម ដែលមិនអាចធ្វើការផ្សព្វផ្សាយដោយបើកចំហ
- មានឧបសគ្គច្រើនក្នុងការឈានជើងចូលក្នុងទីផ្សារការងារក្នុងប្រព័ន្ធ ដោយសារបញ្ហាការងារ ដែលធ្លាប់មានរបស់ពួកគេនៅមានកម្រិត។

**ខ. សម្រាប់អតិថិជន និងពាណិជ្ជករក្រៅប្រព័ន្ធ** (For Customers Of Informal Worker/Trader)

ការរៀបចំកិច្ចសន្យាដោះដូរទំនិញ ឬសេវាកម្មរវាងអតិថិជន និងពាណិជ្ជករក្រៅប្រព័ន្ធអាចនឹងមានការកំណត់ ឬមិនមានការកំណត់អាស្រ័យដោយការព្រមព្រៀងរបស់បុគ្គលទាំងសងខាង ហើយអាចនឹងមិនមានការគាំទ្រពីច្បាប់។

**គ. កាន់តែមានភាពទូលំទូលាយសម្រាប់សង្គម**(For Society More Broadly)

- បាត់បង់ការគ្រប់គ្រងលើគុណភាពផលិតផល និងសេវាកម្មដែលផលិត និងចែកចាយ
- ប្រាក់ឈ្នួល និងតម្លៃការប្រកួតប្រជែងជាមួយអាជីវកម្មក្រៅប្រព័ន្ធ អាចជាមូលហេតុចុះខ្សោយនៃច្បាប់ការងាររបស់កម្មករទៅលើប្រាក់ឈ្នួលអប្បបរមា
- ការងារមិនត្រឹមត្រូវ និងស្ថិតិប្រាក់ចំណូលមិនពិតប្រាកដ ដែលសេដ្ឋកិច្ចក្រៅប្រព័ន្ធបានក្លែងបន្លំ ឬលុបចោលអាចមានផលប៉ះពាល់ដល់ការងារ និងអាជីវកម្មដែលគាំទ្រដោយរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ។

### ១.៣.២. ចំណុចវិជ្ជមាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

**ក. សម្រាប់កម្មករ ឬពាណិជ្ជករក្រៅប្រព័ន្ធ** (For Informal Worker/Traders)

- ប្រាក់ចំណូលជាក់ស្តែងលើសពីបន្ទាត់នៃភាពក្រីក្រ (អាចរកប្រាក់ចំណូលបានលើសពី ១,៩០ដុល្លារក្នុងមួយថ្ងៃមានន័យថា គឺមិនស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រ)
- ទទួលបានការបណ្តុះបណ្តាលជំនាញផ្សេងៗ ការអភិវឌ្ឍចំណេះដឹង និងគំនិតស្មារតី
- មានភាពងាយស្រួលទាំងទីកន្លែង និងពេលវេលានៅក្នុងការងារ(ជាពិសេសស្ត្រី ដែលអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែកូន)
- កាត់បន្ថយឧបសគ្គចំពោះការធ្វើការងារព្រោះភាគច្រើនធ្វើការជាមួយគ្រួសារ និងមិត្តភក្តិ។

**ខ. សម្រាប់អតិថិជន និងពាណិជ្ជករក្រៅប្រព័ន្ធ** (For Coustomers Of Informal Worker/Trader)

តម្លៃទំនិញ និងសេវាកម្មអាចនឹងសមរម្យដែលប្រព្រឹត្តទៅតាមសំណើររបស់អតិថិជន ប្រសិនបើការទូទាត់ គឺជាសាច់ប្រាក់ និងគ្មានវិក្កយបត្រក្នុងគោលបំណងគេចពន្ធ។

**គ. កាន់តែមានភាពទូលំទូលាយសម្រាប់សង្គម**(For Society More Broadly)

- មានការបណ្តុះបណ្តាលបុគ្គលិក និងសហគ្រិនក្នុងការងារ ដែលមិនតម្រូវឲ្យមានការបង្ហាញនៃធនធានហិរញ្ញវត្ថុ។ វាអាចជួយកាត់បន្ថយសម្ពាធរបស់រដ្ឋ និងភ្នាក់ងាររបស់ខ្លួនកំឡុងពេលកាត់បន្ថយចំណាយសាធារណៈ។
- ការអនុគ្រោះពន្ធ គឺការផ្លាស់ប្តូរផលប្រយោជន៍រវាងមិត្តភក្តិ សាច់ញាតិ និងមិត្តរួមការងារក្នុងការចូលរួមកសាងសង្គម។
- ប្រាក់ចំណូលសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានចំណាយទៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ គឺរួមចំណែកជាផ្លូវការទៅក្នុងកំណើនសេដ្ឋកិច្ច តាមរយៈការចែកចាយទំនិញ និងសេវា។

សេដ្ឋកិច្ចក្រៅប្រព័ន្ធបានផ្តល់សុវត្ថិភាព ចំពោះអ្នកដែលបរាជ័យក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ភាពវិជ្ជមានមួយទៀតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺធ្វើឲ្យនិយោជិតមានការងារធ្វើ នៅពេលដែលកម្មវិធីរបស់រដ្ឋាភិបាលមិនទទួលបានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ប្រជាជន ដូច្នេះហើយសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចបំពេញបន្ថែមបានបណ្តោះអាសន្ន។

ទ្រឹស្តីខ្លះបាននិយាយថា សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាដំណាក់កាលចាំបាច់សម្រាប់អភិវឌ្ឍន៍អាជីវកម្មខ្នាតតូច ហើយអាជីវកម្មខ្នាតតូចនេះនឹងមិនអាចរីកចម្រើនបានទេ បើគ្មានសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ លោក Benedict Bellot បានលើកឡើងថា ភាពមិនផ្លូវការ ឬក្រៅប្រព័ន្ធអាចជារយៈពេលនៃការភ្ញាស់របស់ម្ចាស់អាជីវកម្មដែលបានដួលរលំ ឬធ្លាប់បានបរាជ័យ។

## ១.៤. ទំនាក់ទំនងរវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ប្រទេសនីមួយៗនៅលើពិភពលោកមិនថាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍នោះទេ គឺតែងតែគិតពីបញ្ហាសេដ្ឋកិច្ចជាចម្បង ព្រោះសេដ្ឋកិច្ចជាកាតាលីករដ៏សំខាន់ ក្នុងការអភិវឌ្ឍប្រទេសជាតិ។ សេដ្ឋកិច្ចត្រូវបានគេបែងចែកជាពីរប្រភេទគឺ សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

❖ សេដ្ឋកិច្ចក្នុងប្រព័ន្ធ សំដៅទៅលើរាល់សកម្មភាពសេដ្ឋកិច្ចទាំងឡាយណា ដែលស្ថិតនៅក្នុងក្របខណ្ឌច្បាប់ និងមានការទទួលស្គាល់ពីសង្គមអាជ្ញាធរសាធារណៈ ហើយមានការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាល។

❖ សេដ្ឋកិច្ចក្រៅប្រព័ន្ធ សំដៅទៅលើរាល់សកម្មភាពសេដ្ឋកិច្ចទាំងឡាយណា ដែលស្ថិតនៅក្រៅក្របខណ្ឌច្បាប់ និងមិនមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាល និងអាជ្ញាធរសាធារណៈ។

ទោះបីជាមានការបែងចែកនូវសេដ្ឋកិច្ចយ៉ាងណាក្ដីក៏សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅតែមានទំនាក់ទំនងជាមួយគ្នា ហើយទំនាក់ទំនងរវាងសេដ្ឋកិច្ចទាំងពីរនេះ គឺត្រូវបានគេសង្កេតឃើញតាមរយៈទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ ទំនាក់ទំនងមួយទៀត គឺទំនាក់ទំនងនិយោជិតក្រៅប្រព័ន្ធ និងសហគ្រាសក្នុងប្រព័ន្ធ។

### ១.៤.១. ទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ

ប្រភពនៃវត្ថុធាតុដើម និងទំនិញសម្រេច ដែលផ្គត់ផ្គង់សហគ្រាសនៅក្នុងប្រព័ន្ធ គឺភាគច្រើនបានមកពីសហគ្រាសក្រៅប្រព័ន្ធ ព្រោះនៅក្នុងទីផ្សារសេដ្ឋកិច្ចក្រៅប្រព័ន្ធមានការប្រកួតប្រជែងគ្នាខ្លាំង ធ្វើឲ្យតម្លៃទំនិញធ្លាក់ចុះជាហេតុធ្វើឲ្យសហគ្រាសក្នុងប្រព័ន្ធងាយស្រួលក្នុងការស្វែងរកការផ្គត់ផ្គង់វត្ថុធាតុដើម ឬទំនិញដែលមានតម្លៃថោក។

### ១.៤.២. ទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងនិយោជិតក្រៅប្រព័ន្ធ

ភាពលើសនៃកម្លាំងពលកម្ម គឺធ្វើឲ្យការផ្គត់ផ្គង់កម្លាំងពលកម្មមានតម្លៃថោកនៅក្នុងទីផ្សារការងារសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ហេតុដូចនេះធ្វើឲ្យសហគ្រាសក្នុងប្រព័ន្ធមួយចំនួនចង់កាត់បន្ថយការចំណាយលើបុគ្គលិកមួយចំនួន ទើបធ្វើឲ្យមានការជួលកម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជំនួសវិញ។ ក្នុងនោះរួមមានអ្នកបោសសម្អាត អ្នកដឹកជញ្ជូន អ្នកបេះផ្លែឈើជាដើម។

## ១.៥. ស្ថានភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា

### ១.៥.១. ឋានៈការងាររបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ

តាមរយៈការសិក្សាស្រាវជ្រាវ និងការបង្ហាញរបស់អង្គការពលកម្មអន្តរជាតិប្រចាំនៅប្រទេសកម្ពុជា បានធ្វើការបែងចែកឋានៈការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាបួនលំដាប់ថ្នាក់ដូចខាងក្រោម៖

❖ **និយោជក៖** ដំណើរការក្នុងសហគ្រាសមួយ ដោយធ្វើពាណិជ្ជកម្ម ឬប្រកបអាជីពមួយដែលនៅក្នុងអាជីពនោះ មានមនុស្សម្នាក់ ឬច្រើននាក់បានបោះទុនរកស៊ីដែលត្រូវបានគេហៅថាថៅកែ។

❖ **អ្នកប្រកបរបររកស៊ីដោយផ្ទាល់ខ្លួន៖** ដំណើរការក្នុងសហគ្រាសពាណិជ្ជកម្ម ឬប្រកប អាជីវកម្មផ្ទាល់ខ្លួនដោយមិនបានជួលនិយោជិតដែលមានប្រាក់ឈ្នួល។ ស្ត្រីមាននិន្នាការជាអ្នកប្រកបការងារ កាត់ដេរ តម្បាញ សិប្បកម្ម និងប្រកបការងារផ្ទាល់ខ្លួនដូចជាអាជីវកម្មជាដើម។ រីឯបុរស

វិញ ប្រកបការងារក្នុងអាជីវកម្មលក់ដូរ ជួសជុលយានយន្ត ការងារសំណង់ ជាងដែក ជាងឈើធ្វើតុ-ទូ-កៅអី និងសិប្បកម្ម។ អ្នកដទៃទៀត គឺជាអ្នកបើកបររថយន្តឈ្នួល អ្នករត់ម៉ូតូឌុប-ម៉ូតូកង់បី-រ៉ឺម៉កម៉ូតូ ឬកម្មករ។ល។

❖ **និយោជិត៖** ជាមនុស្ស ឬក្រុមមនុស្សដែលធ្វើការឲ្យនិយោជកសាធារណៈ ឬឯកជន ដើម្បីទទួលបានកម្រៃជាប្រាក់ឈ្នួល កម្រៃជើងសារ ឬកម្រៃទូទាត់ទៅតាមបរិមាណការងារជាសាច់ប្រាក់ ឬវត្ថុ។

❖ **អ្នកធ្វើការដែលមិនមានប្រាក់ឈ្នួល៖** ជាសមាជិកគ្រួសារចូលរួមចំណែកធ្វើការងារ ដោយមិនយកកម្រៃក្នុងសហគ្រាសសេដ្ឋកិច្ចមួយ ដែលដំណើរការដោយសាច់ញាតិរស់នៅក្នុងគ្រួសារជាមួយគ្នា។ សម្រាប់ការស្នាក់នៅ ចំណីអាហារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដែលម្ចាស់អាជីវកម្មបានផ្តល់ដល់ពួកគេ គឺមិនត្រូវបានរាប់បញ្ចូលចាត់ទុកថាជាការទូទាត់ប្រាក់ឈ្នួលចំពោះកម្លាំងពលកម្មឡើយ។

### ១.៥.២. ក្រុមមនុស្សធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានមុខរបរ និងការងារជាច្រើនរាប់ពាន់ប្រភេទផ្សេងៗគ្នា។ តាមរយៈការសិក្សា និងវិភាគទៅលើមុខរបរចម្រុះទាំងនោះ អង្គការពលកម្មអន្តរជាតិបានសម្រេចធ្វើការបែងចែកមុខរបររបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធនេះជាបីក្រុមធំៗគឺ៖

❖ **អ្នកប្រកបរបររកស៊ីដោយខ្លួនឯង៖** សំដៅដល់អ្នកដែលប្រកបការងារដោយខ្លួនឯង ឬធ្វើការតែឯង ឬរួមជាក្រុមជាមួយនិយោជិត ឬបុគ្គលិកដែល *មិនមានប្រាក់ឈ្នួល។* ឧទាហរណ៍៖ អាជីវកម្មរត់តាក់ស៊ីពីរនាក់ប្តីប្រពន្ធដោយមានរថយន្តជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលប្តីជាអ្នកបើកបរ និងប្រពន្ធជាអ្នកហៅភ្ញៀវ និងប្រមូលលុយ។ ពួកគាត់ទាំងពីរនាក់ គឺជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង ពីព្រោះថា ពួកគាត់មិនបានស៊ីឈ្នួលបើកឡានឲ្យគេឡើយ ហើយពួកគាត់គឺជាគ្រួសារនឹងគ្នា ដែលប្តីជាតៃកុង ហើយប្រពន្ធជាកម្មករឡានដែលមិនបានយកប្រាក់ឈ្នួល។ ហេតុផលសំខាន់មួយទៀតនោះ គឺការប្រកបរបរអាជីវកម្មរបស់ពួកគាត់មិនបានចុះបញ្ជីពាណិជ្ជកម្មទៀតផង។ ដោយរថយន្តនោះជាទុនវិនិយោគរបស់ពួកគាត់ផ្ទាល់ និងមិនបានស៊ីឈ្នួលបើកឲ្យថៅកែណាម្នាក់ឡើយ បែបនេះនាំឲ្យគេអាចចាត់ទុកពួកគាត់ថាជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង។ បើទោះបីជាឡាននោះគាត់ជួលគេក៏ដោយ ក៏គេនៅតែអាចចាត់ទុកចាត់បញ្ចូលពួកគាត់ថា ជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯងបានដដែល។ តទៅនេះសម្រាប់អ្នកប្រកបរបររកស៊ីដោយខ្លួនឯងគួរតែត្រូវបានគេផ្លាស់មកហៅថាជា "អាជីវករ" វិញ ដោយសម្អាងថា ពួកគាត់បានយកដើមទុនផ្ទាល់របស់គាត់មករកស៊ីដោយឯករាជ្យ និងមានម្ចាស់ការលើខ្លួនឯង ហើយក៏មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់

អ្នកណាម្នាក់ដែរ។ ក្រុមអាជីវករ ទាំងនេះរួមមាន អ្នកលក់ដូរ អ្នកលក់ទូរសព្ទដៃ អ្នកលក់ដូរតាមចិញ្ចើមផ្លូវថ្នល់ អ្នករត់ម៉ូតូឌុប អ្នកផាក់ស៊ីក្លូ...ជាពិសេសអ្នករត់ម៉ូតូកង់បី(តុកតុក) ដែលយើងនឹងលើកយកមកធ្វើជាកម្មវត្ថុសិក្សានៅក្នុងជំពូកក្រោយ។

❖ **ថៅកែក្រៅប្រព័ន្ធ៖** សំដៅដល់និយោជកនៃមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធ។ ឧទាហរណ៍៖ ហាងលក់កាហ្វេដែលមានកម្មកររត់តុចំនួន ៤នាក់ ហើយកម្មករទាំងនោះត្រូវបានថៅកែទូទាត់ប្រាក់ខែជារៀងរាល់ខែ។ ថៅកែដែលជាម្ចាស់ហាងកាហ្វេនោះមិនបានចុះបញ្ជីអាជីវកម្ម និងសុំអាជ្ញាបណ្ណពីក្រសួងពាក់ព័ន្ធឡើយ។ ដូច្នេះមានន័យថា ហាងកាហ្វេ ខាងលើត្រូវបានគេចាត់ទុកជាហាងមួយដែលមានដំណើរការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ នាំឲ្យយើងអាចនិយាយបានថាថៅកែហាងកាហ្វេជា *ថៅកែក្រៅប្រព័ន្ធ*។

❖ **កម្មករក្រៅប្រព័ន្ធ៖** សំដៅដល់កម្មករ និយោជិត ឬអ្នកធ្វើការដែលស្ថិតនៅក្នុងទីផ្សារមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធ ឬអ្នកធ្វើការទាំងឡាយណាដែលមិនមាននិយោជកច្បាស់លាស់ ឬគ្មានកិច្ចសន្យាការងារច្បាស់លាស់ដូចជា អ្នកបម្រើការងារតាមផ្ទះ អ្នកម៉ៅការសំណង់ជាដើម។ យោងតាមការចុះផ្សាយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៩ បានឲ្យដឹងថា នៅក្នុងប្រទេសកម្ពុជាមានកម្មករនិយោជិតសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រមាណ ២,៤លាននាក់ដែលកំពុងបម្រើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។[14]

### ១.៥.៣. លក្ខណៈនៃអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

#### ១.៥.៣.១. ការធ្វើចំណាកស្រុក

ដោយហេតុថា ប្រាក់ចំណូលដែលរកបាន ពុំទាន់គ្រប់គ្រាន់ក្នុងការបំពេញសេចក្តីត្រូវការរបស់ខ្លួន។ ប្រជាពលរដ្ឋភាគច្រើនប្រឈមមុខនឹងភាពក្រីក្រ និងឱកាសការងារមិនគ្រប់គ្រាន់ដែលវាបណ្តាលមកពីកង្វះនូវកម្មសិទ្ធិដីធ្លី ជាហេតុធ្វើឲ្យការប្រកបការងារធ្វើកសិកម្មរបស់ពួកគាត់ស្ថិតនៅក្នុងទ្រង់ទ្រាយតូច ដែលមិនអាចផ្គត់ផ្គង់នៅក្នុងគ្រួសារបានគ្រប់គ្រាន់ ទើបធ្វើឲ្យប្រជាពលរដ្ឋជាច្រើននៅតាមជនបទ ត្រូវបានជំរុញឲ្យធ្វើចំណាកស្រុកមករស់នៅ និងរកការងារធ្វើនៅ ទីប្រជុំជន ឬទីក្រុង ក៏ដូចជាទៅក្រៅប្រទេសផងដែរ ដោយក្តីរំពឹងថា ពួកគាត់នឹងអាចរកប្រាក់ចំណូលបានច្រើនជាងនៅទីជនបទ ដែលអាចធ្វើឲ្យពួកគាត់រួចចាកផុតពីភាពក្រីក្រ និងមាន

[14] ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, *ក្រុមជំនាញរបស់ ILO ចុះមកវាយតម្លៃលើសកម្មភាពប្រែក្លាយសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ឲ្យទៅជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ ២០១៤-២០១៨* (ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ២០១៩)។

ជីវភាពប្រសើរឡើង។ អ្នកខ្លះចាកចេញពីស្រុកតែម្នាក់ឯង បន្សល់ទុកនូវសមាជិកគ្រួសារដទៃទៀតនៅឯស្រុកឲ្យរង់ចាំ និងទទួលប្រាក់បញ្ញើពីខ្លួន។ ខ្លះទៀតសម្រេចចិត្ត ធ្វើចំណាកស្រុកទាំងគ្រួសារតែម្តង។

ការធ្វើចំណាកស្រុកផ្លាស់ទីលំនៅ ក៏ដោយសារតែមានការកើនឡើងនូវការងារក្នុងវិស័យឧស្សាហកម្មផ្នែកកាត់ដេរ និងមានភាពខ្វះខាតនៃការងារនៅក្នុងតំបន់ បានធ្វើឲ្យពួកគាត់ចាកចេញ និងផ្លាស់ទីលំនៅទៅកាន់ទីក្រុង ដើម្បីស្វែងរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ស្របពេលជាមួយគ្នានេះដែរ ក្នុងចំណោមប្រជាពលរដ្ឋទាំងនោះមានប្រជាពលរដ្ឋមួយចំណែកបានធ្វើការក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជា លក់មីឆា លក់បន្លែ លក់ភេសជ្ជៈ រត់ម៉ូតូឌុប និងរត់ម៉ូតូកង់បី(តុកតុក) ជាដើម។ ក្រៅពីការងារក្រៅប្រព័ន្ធប្រជាពលរដ្ឋមួយចំនួនដែលមានជំនាញការងារតិចតួច ក៏អាចប្រកបការងារនៅក្នុងវិស័យក្នុងប្រព័ន្ធផងដែរ ប៉ុន្តែភាគច្រើននៃអ្នកទាំងអស់នោះងាយប្រឈមនឹងការបោកប្រាស់ ឬការកេងប្រវ័ញ្ចលើផលប្រយោជន៍ការងារ និងលក្ខខណ្ឌការងារ ពីព្រោះតែកង្វះនូវចំណេះដឹង។ ក្នុងឆ្នាំ២០១២ ក្នុងចំណោមប្រជាពលរដ្ឋដែលមានការងារធ្វើសរុបនៅក្នុងប្រទេសកម្ពុជាមានប្រជាពលរដ្ឋចំនួន ៦០,២% បានធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ពុំមានស្តង់ដាត្រឹមត្រូវនោះទេ(និយោជិតខ្លះទទួលបានប្រាក់ឈ្នួលតាមមូលដ្ឋាន អត្រាប្រចាំម៉ោង ឬថ្ងៃ អ្នកខ្លះទៀតទទួលបានប្រាក់ឈ្នួលតាមមូលដ្ឋានការងារជាក់ស្តែង ហើយការបើកប្រាក់ឈ្នួលអាចជាប្រាក់សុទ្ធ ឬជាសម្ភារៈប្រដាប់ប្រដាផ្សេងៗជាដើម) ហើយក៏មិនមានប្រាក់ឈ្នួល អប្បបរមាត្រូវបានកំណត់ដោយច្បាប់នៅឡើយទេ លើកលែងតែចំពោះកម្មករនិយោជិតក្នុងវិស័យក្នុងប្រព័ន្ធដូចជា វិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងជាដើម។[15]

### ១.៥.៤. បញ្ហាប្រឈមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានដើរតួយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ចំណូលនៃថវិកាជាតិ។ ជាមួយគ្នានេះបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងកម្លាំងពលកម្មការងារក្រៅប្រព័ន្ធគឺមានការផ្លាស់ប្តូរកន្លែងការងារច្រើនកន្លែងក្នុងពេលតែមួយដោយសារមិនមានឯកសារច្បាស់លាស់ ពិបាកក្នុងការគ្រប់គ្រងកម្មករភាគច្រើនមិនមានជំនាញច្បាស់លាស់ គឺប្រើប្រាស់កម្លាំង និងទទួលបានប្រាក់ឈ្នួលទាប ហើយត្រូវការចំណាយច្រើននៅក្នុងបន្ទុកគ្រួសារ។ ពេលខ្លះបំពេញការងារជួបគ្រោះថ្នាក់ធ្ងន់ធ្ងរមិនមានប្រាក់សម្រាប់ព្យាបាលជំងឺ ឬពេល

[15] ថៃ សុម៉ារី និង ឡា ស៊ីឡាយ "*ការធ្វើចំណាកស្រុក*"(សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៨), ៤០-៤១។

ខ្លះទៀតអ្នកធ្វើការរកចំណូលគ្រោះថ្នាក់រហូតដល់ពិការភាព ឬស្លាប់ ដែលធ្វើឲ្យបាត់បង់នូវប្រាក់ចំណូលគ្រួសារ ព្រមទាំងបន្ថែមបន្ទុកធ្ងន់ក្នុងគ្រួសារឈានទៅរកភាពក្រីក្រ ព្រោះគ្មានអ្វីជាទីពឹង។

សកម្មភាពរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺគ្មានការគ្រប់គ្រងដោយច្បាប់ និងការពារបានល្អនៅឡើយហើយការគ្រប់គ្រងបទបញ្ញត្តិនៅមានលក្ខណៈមិនច្បាស់លាស់ទៀតនោះ។ ជាលទ្ធផលអ្នកធ្វើការក្រៅប្រព័ន្ធបានប្រឈមមុខនឹងបញ្ហាជាច្រើនបែប ជាពិសេសអ្នករត់ម៉ូតូកង់បីដែលគ្មានកន្លែងចំណតត្រឹមត្រូវនៅពេលដែលពួកគាត់ឈប់ចាំទទួលភ្ញៀវ ឬឈប់សម្រាកមួយពេលៗតែងតែរងនូវការរំខានពីសំណាក់អាជ្ញាធរសាធារណៈ និងសន្តិសុខជាដើម។ល។

### ១.៥.៤.១. ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ប្រសិនបើក្រឡេកមកមើលផ្នែកច្បាប់ និងបទបញ្ញត្តិផ្សេងៗនៅកម្ពុជា បទបញ្ញត្តិរបស់រដ្ឋាភិបាល បានបន្ថែមបន្ទុកផ្សេងទៀតដល់ប្រជាជនដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជាអំពើពុករលួយ ការិយាធិបតេយ្យ និងការចំណាយខ្ពស់ក្នុងប្រតិបត្តិការអាជីវកម្ម។ ដើម្បីធ្វើឲ្យ អាជីវកម្មស្ថិតនៅក្នុងប្រតិបត្តិការត្រូវចុះបញ្ជី នៅក្រសួងមានសមត្ថកិច្ចជាច្រើនដូចជា ក្រសួងពាណិជ្ជកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ធានាលេខអត្តសញ្ញាណ ពន្ធប៉ាតង់ និងពន្ធអាករលើតម្លៃបន្ថែម ក្រសួងការងារសម្រាប់អនុម័តលើបទបញ្ជាផ្ទៃក្នុង និងក្រសួងពាក់ព័ន្ធដទៃទៀត ប្រសិនបើសកម្មភាពអាជីវកម្មទាក់ទងនឹងក្រសួងទាំងនោះ។ ករណីសហគ្រាសជាច្រើនបានជ្រើសរើសយកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រតិបត្តិការអាជីវកម្មដោយគ្មានការអនុញ្ញាត និងចុះបញ្ជីត្រឹមត្រូវ ដើម្បីចៀសវាងនូវបទបញ្ញត្តិដ៏ស្មុគស្មាញនានា និងការចំណាយខ្ពស់លើការចុះបញ្ជី។

ការគេចពន្ធ និងកង្វះទំនុកចិត្តលើតម្លាភាពក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលជំរុញឲ្យមានការមិនគោរពច្បាប់។ ភាពងាយរងគ្រោះរបស់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកើនឡើងទ្វេដងពួកគេមិនអាចគោរពតាមច្បាប់ទាំងនោះបានទេ ដោយហេតុថាពួកគេមានចំណូលទាប និងមិនទៀងទាត់។ ម្យ៉ាងទៀតពួកគេតែងតែរងនូវការរំខាន និងការគំរាមកំហែងពីអាជ្ញាធរសាធារណៈទៀតផង។

### ១.៥.៤.២. បញ្ហាទាក់ទងនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្រោមច្បាប់ការងារបច្ចុប្បន្ន អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធទាំងអស់មិនទាន់មានកិច្ចការពារតាមផ្លូវច្បាប់ ឬលក្ខខណ្ឌការងារណាមួយពីសង្គមនៅឡើយទេ។

ប្រជាជនមួយផ្នែកធំ បានប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធដោយមានការបង្កើតអាជីវកម្មផ្ទាល់ខ្លួន និងប្រភេទការងារផ្សេងៗទៀតដែលទទួលបានកម្រៃ ដែលអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានមួយចំណែក។ ការទទួលបាននូវចំណូលមិនទៀងទាត់ បូករួមនឹងភាពក្រីក្រផងនោះ បានធ្វើឲ្យអ្នកប្រកបរបរធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពុំសូវមានលទ្ធភាពទទួលបាននូវសេវាកម្មថែទាំសុខភាព ការអប់រំ និងសកម្មភាពសង្គម វប្បធម៌ និងនយោបាយផ្សេងៗទៀត។ ទន្ទឹមនឹងនេះផងដែរ អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្រត្រូវបានគេប្រមូលផ្តុំ ហើយជាទូទៅ ប្រសិនបើប្រមូលផ្តុំវិញ សមាគមរបស់ពួកគេនៅមានភាពទន់ខ្សោយ កង្វះការយកចិត្តទុកដាក់ កង្វះធនធានមនុស្សដែលអាចបម្រើផលប្រយោជន៍ឲ្យសមាជិកនៅក្នុងក្រុម ជាពិសេសគ្មានប្រព័ន្ធ ឬលក្ខន្តិកៈច្បាស់លាស់។ អ្នកដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានអាជីព និងសកម្មភាពផ្សេងៗគ្នាដែលធ្វើឲ្យពួកគេគ្មានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការប្រមូលផ្តុំ ដូចនេះពួកគេមានសិទ្ធិ និងអំណាចតិចតួចនៅក្នុងសង្គម។

### ១.៥.៥. សារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ទន្ទឹមនឹងការជួបប្រទះនូវបញ្ហាជាច្រើនរបស់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ រួចមកពួកគេក៏ទទួលបានមកវិញនូវអត្ថប្រយោជន៍មួយចំណែកផងដែរ។ ការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់ប្រជាជន និងបានរួមចំណែកយ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចជាតិ។ ស្របពេលជាមួយគ្នានេះដែរ សេដ្ឋកិច្ចក្រៅប្រព័ន្ធបានផ្តល់នូវលក្ខណៈងាយស្រួលដល់ប្រជាជន ក្នុងការឈានជើងចូលទៅកាន់ទីផ្សារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធជាងទីផ្សារក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធតម្រូវឲ្យមានការចុះបញ្ជីអាជ្ញាបណ្ណ និងបង់ពន្ធជូនរដ្ឋជាដើម។ ផ្ទុយមកវិញចំពោះអ្នកធ្វើការនៅក្នុងទីផ្សារសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនតម្រូវឲ្យដូចទៅនឹងទីផ្សារសេដ្ឋកិច្ចក្នុងប្រព័ន្ធនោះទេ ដោយអាជីវករដែលមានដើមទុនតិច និងកម្រិតនៃការអប់រំទន់ខ្សោយក៏អាចប្រកបរបរបានដែរ។ ម្យ៉ាងទៀតការងារទាំងនេះក៏បានផ្តល់ប្រាក់ចំណូលដល់គ្រួសារមួយចំណែកផងដែរ សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារបានមួយកម្រិតទៀត ព្រមទាំងធ្វើឲ្យប្រជាជនមួយចំនួនមានម្ចាស់ការលើខ្លួនឯងជាងមុន។

បន្ថែមពីលើនេះ ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានៅមានការលំបាកនៅឡើយ បើទោះបីជាកំណើនសេដ្ឋកិច្ចខ្លាំងរយៈពេល ២ទសវត្សរ៍ចុងក្រោយក្នុងរង្វង់ ៧% ក៏ដោយក៏គេនៅតែឃើញថាអត្រានៃភាពក្រីក្រនៅតែមានការកើនឡើងដដែល។ ប្រជាជនដែលក្រីក្រ គឺ អសមត្ថភាពក្នុងការឈានជើងចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយសារតែពួកគេមានការអប់រំទន់ខ្សោយ និង

មូលធនតិច ធ្វើឲ្យប្រជាជនក្រីក្រទាំងអស់នោះគ្មានជម្រើសក្រៅពីប្រកបមុខរបរ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពីព្រោះថាសេដ្ឋកិច្ចក្រៅប្រព័ន្ធបានផ្តល់នូវការងារសមស្របសម្រាប់ពួកគាត់ ទោះបីជាគាត់ពុំសូវមានចំណេះដឹងខ្ពស់ ឬមានដើមទុនតិចតួចក៏អាចប្រកបមុខរបរបានដែរ។ ដូច្នេះហើយសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនត្រឹមតែស្រូបយកប្រជាជនដែលមានចំណូលទាបនោះទេ វាថែមទាំងបានចូលរួមចំណែកក្នុងការកាត់បន្ថយនូវភាពក្រីក្រ និងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ប្រជាជនទៀតផង ដូចជាប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃនៅក្នុងគ្រួសារ។

# ជំពូកទី២
# ស្ថានភាពអ្នករត់ម៉ូតូកង់បី
# ក្នុងរាជធានីភ្នំពេញ

# ជំពូកទី២

# ស្ថានភាពអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ

## ២.១. ស្ថានភាពទូទៅក្នុងរាជធានីភ្នំពេញ

### ២.១.១. ទីតាំងភូមិសាស្ត្រ

រាជធានីភ្នំពេញ គឺជាកន្លែងដែលមានកេរ្តិ៍ឈ្មោះល្បីក្នុងការទទួលស្វាគមន៍ភ្ញៀវទេសចរច្រើនជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញ មានទីតាំងស្ថិតនៅប្រសព្វទន្លេធំ ៣ ជាប់ដៃទន្លេ ៤ នៃទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ នៅផ្នែកខាងស្តាំមុខព្រះបរមរាជវាំង។ រាជធានីភ្នំពេញ ក៏ជាច្រកចូលមួយដ៏សំខាន់នៃបណ្តាប្រទេសផ្សេងៗនៅលើពិភពលោក។ ចំពោះលក្ខខណ្ឌធម្មជាតិវិញ នៅរាជធានីភ្នំពេញមានអាកាសធាតុក្តៅពេញមួយឆ្នាំ ដោយគ្រាន់តែមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ កម្រិតសីតុណ្ហភាពមានចាប់ពី ១៨ អង្សារ ដល់ ៣៨ អង្សារសេ (៦៤ ដល់ ១០០ អង្សារហ្វារិនហាយ) គឺសមល្មមអំណោយផលដល់ការរស់នៅរបស់បងប្អូនប្រជាពលរដ្ឋ ទាំងអ្នកមានលំនៅនៅរាជធានីភ្នំពេញ និងអ្នកមកពីតាមបណ្តាខេត្តនានា។ លើសពីនេះរាជធានីភ្នំពេញ បានបង្ហាញនូវវប្បធម៌មួយចំនួន និងមានភាពទាក់ទាញបែបប្រវត្តិសាស្ត្ររួមមាន ព្រះបរមរាជវាំង វិហារព្រះកែវមរកត និងសារមន្ទីជាតិជាដើម។ មិនត្រឹមតែប៉ុណ្ណោះ មានសណ្ឋាគារថ្នាក់ផ្កាយប្រាំ ផ្ទះសំណាក់ ភោជនីយដ្ឋានអន្តរជាតិ ហាងគុយទាវតាមដងផ្លូវ ក្លឹបកម្សាន្តថ្នាក់ក្នុងស្រុក និងក្លឹបឌីស្កូថ្នាក់អន្តរជាតិ។ល។ បរិមាណភោជនីយដ្ឋាន និងសណ្ឋាគារបានរីកវាលដាលគួរឲ្យកត់សម្គាល់នៅប៉ុន្មានឆ្នាំកន្លងទៅនេះ កំណើនភ្ញៀវទេសចរបានកើនឡើងយ៉ាងគំហុកពីមួយឆ្នាំទៅមួយឆ្នាំ។ ច្រកទ្វារចេញចូលអន្តរជាតិផ្លូវគោកចំនួន ៣ ត្រូវបានចាប់ដំណើរការនៅឆ្នាំ ២០០៨ ហើយសព្វថ្ងៃ យើងអាចធ្វើដំណើរតាមផ្លូវអាកាសដោយផ្ទាល់ពីរាជធានីភ្នំពេញទៅទីក្រុងអាស៊ានមួយចំនួនផងដែរ។ ប្រព័ន្ធផ្លូវគោកត្រូវបានជួសជុល និងធ្វើឲ្យប្រសើរឡើងបន្តិចម្តងៗ ធ្វើឲ្យការធ្វើដំណើរមានភាពងាយស្រួលរួមទាំងការដឹកជញ្ជូនតាមជើងយន្តហោះក្នុងស្រុក និងការបម្រើសេវាទៀងទាត់តាមរថយន្តក្រុងពីរាជធានីទៅទីក្រុងធំៗដូចជាក្រុងព្រះសីហនុ និងកំពង់ចាមជាដើម។[16]

### ២.១.២. កំណើនប្រជាជន

អត្រាកំណើនប្រជាជន នៅក្នុងទីក្រុងភ្នំពេញបានរក្សានៃការកើនឡើងជាវិជ្ជមាន ចាប់តាំងពីឆ្នាំ ១៩៨០ បន្ទាប់ពីមានការធ្លាក់ចុះនូវចំនួនប្រជាជនក្នុងឆ្នាំ ១៩៧៨។ តាមប្រវត្តិសាស្ត្រ ទីក្រុង

[16] គេហទំព័រ http://phnompenh.gov.kh/phnom-penh-city/ (ចូលទស្សនាថ្ងៃទី១៤ ឧសភា ២០២០)។

ភ្នំពេញមានការកើនឡើងនូវប្រជាជនមកវិញគួរឲ្យកត់សម្គាល់ពេញមួយឆ្នាំ ដោយចំនួនប្រជាជនមានការកើនឡើងពីរដងក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និង១៩៩០ ហើយចាប់តាំងពីឆ្នាំ ១៩៨០មក យើងសង្កេតឃើញថា ប្រជាជនក្នុងទីក្រុងភ្នំពេញ គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។

យោងតាមការចុះផ្សាយរបស់សាលារាជធានីភ្នំពេញបានបង្ហាញថា រាជធានីភ្នំពេញ គឺជាទីក្រុងធំជាងគេបំផុតនៃប្រទេសកម្ពុជា ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម សេដ្ឋកិច្ច នយោបាយ វប្បធម៌ និងការទូត។ ប្រជាជននៅរាជធានីភ្នំពេញមានចំនួន ១.៤៧០.៣០៣នាក់(ឆ្នាំ២០១៨) ដែលមានដង់ស៊ីតេប្រជាជន ២.២១៣នាក់ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ។[17] បើយោងតាមការធ្វើជំរឿន ២០១៩ ដែលចេញផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ បានឲ្យដឹងថា នៅក្នុងរាជធានីភ្នំពេញមានចំនួនប្រជាជនសរុប ២.១២៩.៣៧១នាក់(ឆ្នាំ២០១៩) ដែលមានដង់ស៊ីតេប្រជាជន ៣.១៣៦នាក់ក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ។ ប្រជាជននៅក្នុងទីក្រុងភ្នំពេញមានការកើនឡើងយ៉ាងឆាប់រហ័សពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតែមានការផ្លាស់ប្តូរទីលំនៅពីជនបទមកកាន់ទីក្រុង ដើម្បីស្វែងរកឱកាសការងារ បន្តការសិក្សា និងប្រកបរបរអាជីវកម្មផ្សេងៗ។ល។

### ២.១.៣. ការកើនឡើងនៃយានយន្តក្នុងទីក្រុងភ្នំពេញ

ការកើនឡើងដ៏ឆាប់រហ័សនៃប្រជាជនក្នុងទីក្រុងភ្នំពេញ និងការកើនឡើងនៃផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនម្នាក់ៗ បានធ្វើឲ្យមានកំណើនយានយន្តដ៏ច្រើនលើដងផ្លូវនាពេលបច្ចុប្បន្ន។ ចំនួនរថយន្តចុះបញ្ជីនៅក្នុងទីក្រុងភ្នំពេញមានការកើនឡើងឥតឈប់ឈរ ដែលមានកំណើនមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៨ ចំនួនយានយន្តនៅរាជធានីភ្នំពេញ មានការកើនឡើងរហូតដល់ជាង ២.១៩លានគ្រឿង ក្នុងនោះចំនួនរថយន្តគ្រប់ប្រភេទមានចំនួន ៤៨ម៉ឺនគ្រឿង ម៉ូតូមានចំនួន ១.៧០លានគ្រឿង និងរ៉ឺម៉កកង់បីមានចំនួន ១ម៉ឺន១ពាន់គ្រឿងដែលបានចុះបញ្ជី។ របាយការណ៍នៃក្រសួងសាធារណការ និងដឹកជញ្ជូនបានបង្ហាញឲ្យដឹងថា គិតត្រឹមខែកក្កដា ឆ្នាំ ២០១៨ ចំនួនយានយន្តមានចំនួន ៤.៥២២.១១៩គ្រឿង ក្នុងនោះសម្រាប់ម៉ូតូមានចំនួន ៣.៨៦៥.២៨៩គ្រឿង និងរថយន្តចំនួន ៦៥៦.៨៣០គ្រឿង។[18]

យោងតាមស្ថិតិរបស់សាលារាជធានីភ្នំពេញ ពីខែសីហា ២០០៦ ដល់ខែសីហា ២០១១ រថយន្តដែលចុះបញ្ជីសរុបមានចំនួន ៦៧០.០៩១គ្រឿង ដែលក្នុងនោះទោចក្រយានយន្តមានចំនួន

[17] សាលារាជធានីភ្នំពេញ, (ភ្នំពេញ៖ សាលារាជធានីភ្នំពេញ), អាចរកបាននៅ http://phnompenh.gov.kh/phnom-penh-city/facts/ (ចូលទស្សនាថ្ងៃទី១៤ ឧសភា ២០២០)។

[18] ជន រស្មី និង នន់ ឌីយ៉ា, "ការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ," (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩), ២៥។

ច្រើនជាងគេ ៥៦២.៦២៣គ្រឿង ស្មើនឹង៨៩% នៃចំនួនយានយន្តដែលចុះបញ្ជីសរុប ប៉ុន្តែចំនួននេះនៅបន្តកើនឡើងជារៀងរាល់ឆ្នាំ។[19]

តារាងទី២.១៖ ស្ថិតិចំនួនយានយន្ត (ខែសីហា ២០០៦ ដល់ខែសីហា ២០១១)

| ល.រ | ប្រភេទ | ចំនួនចុះបញ្ជី |
|---|---|---|
| ១ | រថយន្តធុនតូច | ៩៤.៧៨២គ្រឿង |
| ២ | រថយន្តធុនធំ | ៨.២១៣គ្រឿង |
| ៣ | ទោចក្រយានយន្ត | ៥៦២.៦២៣គ្រឿង |
| ៤ | ត្រីចក្រយានយន្ត | ១.១៣៧គ្រឿង |
| ៥ | ទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក | ៣.៣៣៦គ្រឿង |

*ប្រភព៖ គេហទំព័រផ្លូវការរបស់សាលារាជធានីភ្នំពេញ*

### ២.១.៤. គមនាគមន៍ផ្លូវគោកក្នុងរាជធានីភ្នំពេញ

ក្នុងពេលបច្ចុប្បន្នគេសង្កេតឃើញថា រាជធានីភ្នំពេញការធ្វើចរាចរណ៍មានសកម្មភាពមមាញឹកជាងតាមបណ្ដាខេត្តនានា ដោយសារការកើនឡើងនៃចំនួនប្រជាជន។ សម្រាប់មន្ត្រីរាជការ ទៅបំពេញការងារនៅតាមបណ្ដាស្ថាប័នរដ្ឋ ឬក្រសួងនីមួយៗ ប្រជាពលរដ្ឋធ្វើដំណើរទៅបំពេញការងារក្នុងក្រុមហ៊ុនឯកជន ឬអង្គការ និងប្រកបរបរអាជីវកម្មប្រចាំថ្ងៃជាដើម។ ប្រព័ន្ធផ្លូវផ្ដល់ចូលរួមចំណែក បង្កើតការងារជូនប្រជាពលរដ្ឋធ្វើ ដោយផ្ដល់សេវាកម្មដឹកអ្នកដំណើរពីកន្លែងមួយទៅកន្លែងមួយតាមទោចក្រយានយន្ត ត្រីចក្រយានយន្តមានរ៉ឺម៉កកង់បី(កង់បីខ្មែរ) ម៉ូតូកង់បី (តុកតុក) និងរថយន្តឈ្នួល។ ចំណែកឯក្រុមហ៊ុនអាជីវកម្មប្រើប្រាស់ឡានធំតូច ដើម្បីផ្ដល់សេវាកម្មដឹកជញ្ជូន ឬដឹកទំនិញរបស់សហគ្រាសផ្ទាល់ខ្លួនដែលបានផលិតរួចរាល់ទៅកាន់ទីផ្សារ។

ដូច្នេះដើម្បីរក្សាផលប្រយោជន៍រួមទាំងសេចក្ដីសុខសុវត្ថិភាពនៅតាមដងផ្លូវ និងបញ្ចៀសរាល់បញ្ហាដែលកើតមានឡើង អ្នកបើកបរទាំងអស់ត្រូវគោរពច្បាប់ និងប្រកាន់ខ្ជាប់នូវតួនាទីជាប្រជាពលរដ្ឋល្អ ចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។[20]

បណ្ដាផ្លូវនៅរាជធានីភ្នំពេញប្រៀបបានទៅនឹងសរសៃឈាមមិនអាចកាត់ផ្ដាច់បាន ជារៀងរាល់ថ្ងៃប្រជាពលរដ្ឋធ្វើដំណើរ ដឹកជញ្ជូនទំនិញ និងសេវាកម្មផ្សេងៗ សម្រាប់ដំណើរការសេដ្ឋកិច្ច

[19] សាលារាជធានីភ្នំពេញ, http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២០)។

[20] ដូច១៨, ទំព័រ ២៣-២៤។

របស់ប្រទេសកម្ពុជាទាំងមូល ហើយវាជាផ្នែកមួយដ៏សំខាន់សម្រាប់ជាស្ពានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចគ្រួសាររបស់ប្រជាពលរដ្ឋផងដែរ។ ជាក់ស្តែងដូចជាអ្នកប្រកបរបររត់ម៉ូតូកង់បី(តុកតុក) ដែលមុខរបរនេះអាស្រ័យទៅលើស្ថានភាពផ្លូវ។ បច្ចុប្បន្ននេះ គមនាគមន៍ផ្លូវគោករាជធានីភ្នំពេញមានប្រវែងសរុប ១.៣៧៩.៨៤៧ម៉ែត្រ ដោយគិតបញ្ចូលទាំងប្រភេទផ្លូវកៅស៊ូ AC ផ្លូវកៅស៊ូ DBST និងផ្លូវបេតុងនានាតាមបណ្តាខណ្ឌនីមួយៗ។[21]

តារាងទី២.២៖ ប្រវែងបណ្តាញផ្លូវរាជធានីភ្នំពេញ (គិតជាម៉ែត្រ)

| បរិយាយ | ផ្លូវកៅស៊ូAC | ផ្លូវកៅស៊ូDBST | ផ្លូវបេតុង | សរុប |
|---|---|---|---|---|
| ភ្នំពេញ | ២១៥.២៨៦ | ២៧៩.៧៥៣ | ២០៦.៧៣០ | ១.៣៧៩.៨៤៧ |
| ខណ្ឌដូនពេញ | ២៩.៨០០ | ១២.៧៣០ | ១.៦៨៩ | ៤៣.៨១០ |
| ខណ្ឌចំការមន | ២៩.៥២១ | ៥៣.៦៩៦ | ២១.៣៧៧ | ១០៥.៥២៨ |
| ខណ្ឌ៧មករា | ២៩.៨០០ | ១២.៧៣០ | ១.៦៨៩ | ២២.២៦៤ |
| ខណ្ឌទួលគោក | ៥.៥០០ | ៦៩.០៦៧ | ៣២.៨៥៣ | ១១៧.៩២៤ |
| ខណ្ឌមានជ័យ | ១១.៩៨០ | ១៩.៧២០ | ៥៧.៩៥៣ | ១៩៣.៨៩០ |
| ខណ្ឌដង្កោ | _ | ៣៨.៧៨៨ | ២២.០៦៧ | ៩៥១.៧៦៧ |
| ខណ្ឌសែនសុខ | _ | ៣.៨៦០ | ៧.៧១០ | ១០៥.៥២៨ |
| ខណ្ឌឫស្សីកែវ | ៧.០២០ | ១៨.៩០៩ | ៦២.២៩១ | ១៨៦.៥២៨ |

*ប្រភព៖ គេហទំព័រផ្លូវការរបស់សាលារាជធានីភ្នំពេញ*

### ២.១.៥. មធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ

មុនឆ្នាំ២០១៩ ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងភ្នំពេញភាគច្រើនជ្រើសរើសយកមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនដូចជា ឡាន ឬម៉ូតូ សម្រាប់ការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតដោយសារតែការប្រើប្រាស់មធ្យោបាយផ្ទាល់ខ្លួនមានភាពងាយស្រួល រហ័ស ចំណាយតិច និងអាចនាំពួកគេទៅដល់កន្លែងដែលចង់ទៅ។[22]

[21] សាលារាជធានីភ្នំពេញ, http://phnompenh.gov.kh/phnom-penh-city/facts/notable-data/ (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២០)។

[22] មាស វុទ្ធី, "សេវាដឹកជញ្ជូនសាធារណៈរាជធានីភ្នំពេញ," (សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩), ២៨។

ក្នុងឆ្នាំ២០១៩ នៅទីក្រុងភ្នំពេញមានត្រីចក្រយានយន្តប្រមាណ ៣៥,២១៨គ្រឿងកំពុងធ្វើចរាចរណ៍លើដងផ្លូវដែលបានចុះបញ្ជី។ ប៉ុន្តែសម្រាប់ប្រជាពលរដ្ឋមួយចំនួនដែលគ្មានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ភាគច្រើនបានប្រើប្រាស់ សេវាម៉ូតូឌុប ឡានតាក់ស៊ី រ៉ឺម៉កកង់បី(កង់បីខ្មែរ) ឬម៉ូតូកង់បី(តុកតុក) ក្នុងការធ្វើដំណើរ ដែលគេអាចហៅបាននៅតាមចិញ្ចើមផ្លូវ និងនៅមុខផ្សារ ឬកន្លែងដែលមានមនុស្សអ៊ូអរ។ ដោយសារតែពេលបច្ចុប្បន្ននេះមានការរីកចម្រើនខាងបច្ចេកវិទ្យាលើទូរសព្ទដៃបានបង្កើតឲ្យមានកម្មវិធីទូរសព្ទដែលអាចឲ្យអ្នកដំណើរអាចហៅ ម៉ូតូឌុប ឡានតាក់ស៊ី និងម៉ូតូកង់បី(តុកតុក)បានតាមរយៈទូរសព្ទដៃ ដែលវាបានបង្កឲ្យមានភាពងាយស្រួល និងឆាប់រហ័សក្នុងការស្វែងរកមធ្យោបាយដឹកជញ្ជូនណាមួយដែលពួកគាត់ចង់ប្រើប្រាស់។ ជាក់ស្តែងក្នុងទីក្រុងភ្នំពេញផ្នែកសេវាដឹកជញ្ជូនដែលមានភាពមមាញឹកជាងគេនោះ គឺសេវាកម្មដឹកជញ្ជូនតាមម៉ូតូកង់បី(តុកតុក) ដែលមានភាពងាយស្រួលក្នុងការធ្វើដំណើរប្រកបដោយសុវត្ថិភាព និងមានតម្លៃសមរម្យដល់អតិថិជនជាអ្នកប្រើប្រាស់សេវាមួយនេះ។

## ២.២. ស្ថានភាពអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ

មុខរបររត់ម៉ូតូកង់បី(តុកតុក) គឺជាមុខរបរមួយដែលកំពុងពេញនិយមជាងគេក្នុងចំណោមការងារក្រៅប្រព័ន្ធ ដែលវាជួយបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាពលរដ្ឋជាអ្នកប្រកបមុខរបរនេះឲ្យមានភាពប្រសើរឡើង ស្របទៅនឹងប្រទេសកំពុងអភិវឌ្ឍន៍។ មូលហេតុនៃការពេញចិត្ត និងនិយមប្រើប្រាស់សេវាដឹកជញ្ជូនតាមម៉ូតូកង់បីនេះ គឺវាមានសេវាលឿនរហ័សទាន់ចិត្ត ពុំសូវកកស្ទះចរាចរ និងតម្លៃសមរម្យផងដែរ។

អ្នកប្រកបមុខរបររត់ម៉ូតូកង់បី(តុកតុក) ត្រូវបានកំណត់ថាជាអ្នកដែលរកស៊ីលក់នូវសេវាកម្មដឹកជញ្ជូនភ្ញៀវខ្នាតតូចនៅតាមដងផ្លូវសាធារណៈ ដោយគ្មានទីតាំង(ចំណត)ត្រឹមត្រូវ និងអចិន្ត្រៃយ៍។ អ្នករត់ម៉ូតូកង់បី(តុកតុក) ត្រូវបានគេគិតថាជាអ្នកដែលនៅមួយកន្លែងសម្រាប់ទទួលការហៅពីភ្ញៀវដែលពួកគាត់ចង់ទៅ កន្លែងនោះមានដូចជា មុខផ្សារ មុខហាងកាហ្វេ ភោជនីយដ្ឋាន ហាងបាយ-គុយទាវ នៅចិញ្ចើមផ្លូវ ក្រោមម្លប់ដើមឈើជាដើម ដែលកន្លែងទាំងអស់នោះអាចចតម៉ូតូកង់បីបានដោយពុំមានការហាមឃាត់ ឬបណ្តេញចេញដោយ សន្តិសុខហាង ឬអាជ្ញាធរ សាធារណៈ។ ប៉ុន្តែពួកគាត់ក៏ត្រូវបានចាត់ទុកថាជាអ្នករត់ម៉ូតូកង់បី(តុកតុក) ចល័តផងដែរ ប្រសិនបើគាត់ផ្លាស់ប្តូរទីតាំងចំណតរៀងរាល់ពេល ដោយពួកគាត់ធ្វើការបើកបរម៉ូតូកង់បីចល័តពីទីតាំងមួយទៅទីតាំងមួយទៀត ដើម្បីស្វែងរកអតិថិជន ឬភ្ញៀវដែលពុំមានការកក់ហៅទុកជាមុន។

### ២.២.១. កត្តាជំរុញឲ្យប្រកបមុខរបររត់ម៉ូតូកង់បី

កត្តាជាច្រើនបានជំរុញឲ្យប្រជាជនមួយចំនួន ត្រូវសម្រេចចិត្តប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បីតាមដងផ្លូវសាធារណៈក្នុងរាជធានីភ្នំពេញ ទោះបីជាមុខរបរមួយនេះមិនមានការចុះបញ្ជីត្រឹមត្រូវក៏ដោយ ក៏គេសង្កេតឃើញថាក្នុងប្រទេសកម្ពុជាយើង ពិសេសនៅទីក្រុងភ្នំពេញ គឺមានការកំពុងពេញនិយមយ៉ាងខ្លាំងទៅលើមុខរបរ(ដឹកជញ្ជូនក្រៅប្រព័ន្ធ) រត់ម៉ូតូកង់បីមួយនេះ។ តាមការសិក្សាស្រាវជ្រាវ និងសង្កេតមើលតាមបច្ចុប្បន្នភាពរបស់អ្នករត់ម៉ូតូកង់បីនៅក្នុងរាជធានីភ្នំពេញកន្លងមក បានឲ្យដឹងអំពីកត្តាដែលជំរុញឲ្យពួកគាត់ទាំងអស់នោះសម្រេចចិត្តជ្រើសយកមុខរបរនេះ ដើម្បីជាប្រភពចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ក្នុងនោះយើងឃើញមានដូចជា ពួកគាត់ពុំមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបមុខរបរផ្សេង ពុំមានចំណេះដឹង និងជំនាញពិតប្រាកដ គ្មានជម្រើស ការមើលឃើញទីផ្សារម៉ូតូកង់បីមានតម្រូវការច្រើន មានភាពងាយស្រួលក្នុងការចាប់ផ្ដើម និងទទួលបានប្រាក់ចំណូលអាចផ្គត់ផ្គង់ជីវភាពគ្រួសារបាន មានសិទ្ធិសេរីភាពពេញលេញ ឬមានភាពឯករាជ្យលើខ្លួនឯង ងាយស្រួលក្នុងការការពារខ្លួន ហើយមានសុវត្ថិភាពក្នុងការធ្វើដំណើរទៅលេងស្រុកម្ដងៗ។ល។ ជាពិសេស មុខរបររត់ម៉ូតូកង់បី(តុកតុក) តាមដងផ្លូវសាធារណៈជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារ ដោយសារមិនតម្រូវឲ្យមានដើមទុនច្រើនក្នុងការចាប់ផ្ដើមមុខរបរនេះ និងមិនចាំបាច់ត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មផ្សេងៗដែលត្រូវចំណាយទាំងថវិកា និងពេលវេលាក្នុងការបំពេញសំណុំបែបបទផ្សេងៗព្រមទាំងអាចគេចវេសន៍ពីការបង់ពន្ធផ្សេងៗជាដើម។

### ២.២.២. អត្ថប្រយោជន៍នៃការរត់ម៉ូតូកង់បី

ប្រជាពលរដ្ឋជាច្រើននៅក្នុងប្រទេសកម្ពុជា បានចាប់យកនូវការងារផ្សេងៗគ្នាដើម្បីរកចំណូលមកផ្គត់ផ្គង់ជីវភាពគ្រួសាររៀងៗខ្លួន មានប្រជាពលរដ្ឋខ្លះធ្វើការនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ហើយប្រជាពលរដ្ឋខ្លះទៀតក៏ធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ យោងតាមការចុះផ្សាយរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៤ មករា ២០១៨ បានឲ្យដឹងថា ការលូតលាស់នៃផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺបានចូលរួមផ្ដល់ការងារដល់ពលរដ្ឋកម្ពុជាផងដែរ តាមរយៈការទទួលបានឱកាសចូលបម្រើការងារតាមវិស័យផ្សេងៗ ដែលពាក់ព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ជាពិសេសអ្នករត់ម៉ូតូកង់បី បានចូលរួមក្នុងការកាត់បន្ថយនូវភាពក្រីក្របានមួយកម្រិតផងដែរ ដោយពួកគាត់បានជួយលើកកម្ពស់នូវកម្រិតជីវភាពគ្រួសាររបស់ពួកគាត់។ រាល់ប្រាក់ចំណូលទាំងអស់របស់អ្នករត់ម៉ូតូ

កង់បីដែលបានមក មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ជូនកូនៗទៅសាលារៀន និងថវិកាគ្រប់គ្រាន់សម្រាប់ថ្លៃម្ហូបអាហារ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃសម្រាប់គ្រួសាររបស់ពួកគាត់។[23]

បើយើងក្រឡេកទៅមើលជ្រុងមួយទៀតនៃផលប្រយោជន៍ ដែលអ្នករត់ម៉ូតូកង់បីផ្តល់ឲ្យយើងឃើញថា ការរត់ម៉ូតូកង់បីមិនត្រឹមតែជាប្រភពចំណូលរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែវាធ្វើឲ្យប្រទេសយើងមានភាពទំនើបផ្នែកសេវាដឹកជញ្ជូនខ្នាតតូចដូចប្រទេសអភិវឌ្ឍន៍មួយចំនួនដែរ។ ជាពិសេស មិនថាតែអ្នកដែលមានកម្រិតជីវភាពធូរធារនោះទេ សូម្បីតែអ្នកដែលមានកម្រិតជីវភាពមធ្យម និងកម្រិតទាបក៏អាចប្រើប្រាស់នូវសេវាដឹកជញ្ជូនតាមម៉ូតូកង់បី(តុកតុក) នេះបានដូចគ្នាទាំងអស់ ពីព្រោះការធ្វើដំណើរតាមម៉ូតូកង់បី(តុកតុក) នេះមានតម្លៃធូរថ្លៃជាងតាក់ស៊ី សុវត្ថិភាពជាងម៉ូតូឌុប។ រាល់ការធ្វើដំណើរទាំងអស់តាមម៉ូតូកង់បីទាំងអតិថិជន និងម្ចាស់ម៉ូតូកង់បីមិនពិបាកក្នុងការតថ្លៃ(ម្ចាស់ម៉ូតូកង់បីធ្វើការកាត់ថ្លៃហួសហេតុ ឬទារថ្លៃមិនសាកសមនឹងទីតាំងចម្ងាយផ្លូវ) ជាពិសេស វាមានភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលចង់ទៅទិញទំនិញ ឬអីវ៉ាន់ និងមានគ្នា២ទៅ ៣នាក់ អាចធ្វើដំណើរតាមម៉ូតូកង់បីបានយ៉ាងងាយស្រួល និងមានសុវត្ថិភាពទៀតផង។

### ២.២.៣. បញ្ហាប្រឈមផ្សេងៗ

ក្រៅពីផលប្រយោជន៍ដែលពួកគាត់ទទួលបានពីមុខរបរមួយនេះ ពួកគាត់ក៏បានជួបប្រទះនូវបញ្ហាប្រឈមផ្សេងៗជាច្រើនផងដែរ។ បញ្ហាចម្បងដែលពួកគាត់កំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះ គឺបញ្ហាពុំសូវសម្បូរអតិថិជន ឬភ្ញៀវជិះម៉ូតូកង់បី ដែលបណ្តាលមកពីមានជំងឺរាតត្បាតប្រភេទថ្មី ដែលត្រូវបានគេដាក់ឈ្មោះថា ជំងឺកូវីដ-១៩(COVID-19) ហើយត្រូវបានគេរកឃើញដំបូងគេនៅក្នុងទីក្រុងវូហាន ប្រទេសចិន បានវាយលុកទូទាំងពិភពលោក ក្នុងនោះប្រទេសកម្ពុជាយើងក៏បានរកឃើញអ្នកដែលមានផ្ទុកនូវជំងឺនេះផង ទើបធ្វើឲ្យរាជរដ្ឋាភិបាលសម្រេចចិត្តបិទដើងហោះហើរ និងផ្អាកបណ្តោះអាសន្ននៅកន្លែងកម្សាន្តផ្សេងៗ រោងកុន KTV សាលារៀនគ្រប់កម្រិត ផ្អាកជួបជុំរាល់កម្មវិធីសាសនាជាដើម ដើម្បីទប់ស្កាត់នូវការរីករាលដាលនៃជំងឺនេះបូករួមជាមួយនឹងប្រជាពលរដ្ឋមួយចំនួនធំដែលសម្រេចចិត្តស្នាក់នៅក្នុងផ្ទះផងនោះ ដែលវាជាហេតុធ្វើឲ្យនៅពេលបច្ចុប្បន្ននេះពុំសូវសម្បូរអតិថិជន ឬភ្ញៀវ ប្រើប្រាស់នូវសេវាដឹកជញ្ជូនតាមម៉ូតូកង់បីដែលជាបញ្ហាប្រឈមដ៏សំខាន់របស់អ្នករត់ម៉ូតូកង់បីទាំងអស់ មិនអាចរកនូវប្រាក់ចំណូលបានដូច

[23] ហួត សុធារ៉ា, *វត្តមាន PassApp ធ្វើឲ្យជីវភាពអ្នករត់ម៉ូតូកង់បីធូរធារជាងមុន ទោះបច្ចុប្បន្នមានការប្រកួតប្រជែងក៏ដោយ* (ភ្នំពេញ៖ Business Cambodia [អាជីវកម្មនៅប្រទេសកម្ពុជា] ២០១៩), អាចរកបាននៅ https://www.business-cambodia.com/article /7670 (ចូលទស្សនាថ្ងៃទី១១ ឧសភា ២០២០)។

ពីមុន។[24] បញ្ហាសំខាន់មួយទៀតនោះ គឺអ្នករត់ម៉ូតូកង់បីភាគច្រើនពុំមានទីតាំងសម្រាប់ចតជាអចិន្ត្រៃយ៍នៅឡើយ ដែលជាហេតុធ្វើឲ្យពួកគាត់ពិបាកក្នុងការរក្សាអតិថិជន ឬភ្ញៀវរបស់ខ្លួន។

ទោះបីជាអ្នករត់ម៉ូតូកង់បីមួយចំនួនមានកន្លែងចំណតត្រឹមត្រូវយ៉ាងណាក៏ដោយក៏ពួកគាត់ទាំងនោះ ត្រូវបង់ថ្លៃសម្រាប់កន្លែងចតម៉ូតូកង់បីរបស់ពួកគាត់ដដែល។ ការប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បីនេះមិនត្រូវបានយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលដូចអ្នកដែលធ្វើការ នៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធនោះទេ ដែលធ្វើឲ្យពួកគាត់ទាំងអស់ពុំបានទទួលនូវរបបសន្តិសុខសង្គម និងមិនទទួលបាននូវការធានារ៉ាប់រងទាំងសុខភាព និងអាយុជីវិត។ ពិសេសជាងនេះទៅទៀតនោះពួកគាត់ បែរជាទទួលបានមកវិញនូវការគំរាមកំហែងគាបសង្កត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចជាដើម។

លើសពីនេះទៅទៀត លុយកាក់ក៏ជាបញ្ហាដ៏ធំដែលពួកគាត់ជួបប្រទះផងដែរ។ ពួកគាត់លំបាកក្នុងការទាក់ទងជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ដោយសារតែពួកគាត់ពុំសូវយល់ដឹងអំពីប្រតិបត្តិការ ផែនការកម្ចី សន្សំជាដើម ជាហេតុធ្វើឲ្យពួកគាត់ត្រូវប្រើប្រាស់ប្រាក់សន្សំទាំងអស់របស់ពួកគាត់ដើម្បីចាប់ផ្តើមអាជីវកម្មខ្លួន ឬត្រូវខ្ចីពីអ្នកចងការប្រាក់ក្នុងអត្រាការប្រាក់ខ្ពស់។

នៅមានបញ្ហាតូចៗជាច្រើនទៀតដែលអ្នករត់ម៉ូតូកង់បីទាំងអស់នោះជួបប្រទះដូចជា បញ្ហាអាកាសធាតុមិនទៀងទាត់ ជួនភ្លៀង ជួនក្តៅខ្លាំង ដែលជាហេតុបណ្តាលឲ្យអតិថិជន ឬភ្ញៀវរបស់ពួកគាត់ថយចុះ។ ម្យ៉ាងវិញទៀត គឺការកកស្ទះចរាចរណ៍ដែលយើងទាំងអស់គ្នាបានដឹងរួចមកហើយថា នៅក្នុងទីក្រុងភ្នំពេញយើងនេះបញ្ហាចរាចរណ៍ជាបញ្ហាសំខាន់សម្រាប់អ្នកធ្វើដំណើរទាំងអស់ជាពិសេស គឺអ្នកដែលប្រកបមុខរបររត់ម៉ូតូកង់បីនេះតែម្តង ដែលវាបង្កឲ្យមានភាពយឺតយ៉ាវក្នុងការបម្រើសេវាដឹកជញ្ជូនដល់អតិថិជន ដែលធ្វើឲ្យអតិថិជនមួយចំនួនមានការរអ៊ូរទាំក្នុងការមកទទួលមិនទាន់តម្រូវការ។

[24] តាំង កែវរតនា, *With Tourism Declines, Tuk-Tuk Drivers Are Down and Out in Phnom Penh* [ជាមួយភ្ញៀវទេសចរធ្លាក់ចុះអ្នករត់តុកតុក បានធ្លាក់ចុះ និងចាកចេញពីទីក្រុងភ្នំពេញ] (ភ្នំពេញ៖ VOD [វីអូឌី] ២០២០) អាចរកបាននៅ https://vodenglish.news /tag/tuk-tuk-drivers/ (ចូលទស្សនាថ្ងៃទី១១ ឧសភា ២០២០)។

# ជំពូកទី៣

# ការវិភាគទិន្នន័យ និង

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការវិភាគទិន្នន័យ និងលទ្ធផលស្រាវជ្រាវ

ការវិភាគនេះធ្វើឡើង ដើម្បីពិនិត្យទៅលើស្ថានភាពនៃអ្នករត់ម៉ូតូកង់បី ក្នុងរាជធានីភ្នំពេញ ក្នុងការលើកកម្ពស់កម្រិតជីវភាពគ្រួសាររបស់ពួកគាត់ ដែលរួមមានចំណុចសំខាន់ៗមួយចំនួន ដូចជា អាយុ រយៈពេលក្នុងការប្រកបមុខរបរ ស្ថានភាពគ្រួសារ ចំនួនសមាជិកក្នុងបន្ទុកគ្រួសារ កម្រិតអប់រំ កត្តាជំរុញឲ្យពួកគាត់សម្រេចចិត្តប្រកបមុខរបរនេះ បញ្ហាដែលបានជួបប្រទះនៅពេលចាប់ផ្ដើម និងពេលដំណើរការមុខរបរមួយនេះព្រមជាមួយ និងប្រាក់ចំណូល-ចំណាយប្រចាំថ្ងៃ និងប្រាក់សន្សំប្រចាំខែរបស់ពួកគាត់ដែលរកបានពីមុខរបរមួយនេះដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ។ បន្ថែមពីលើនេះទៀត វានឹងបង្ហាញឲ្យឃើញពីចំណុចខ្លាំង ចំណុចខ្សោយ ការគំរាមកំហែង និងឱកាសផ្សេងៗទៀតដែលអ្នករត់ម៉ូតូកង់បី(តុកតុក) ជួបប្រទះតាមរយៈការវិភាគSWOT។

## ៣.១. ការវិភាគបែបពិពណ៌នា

ការប្រមូលទិន្នន័យសម្រាប់ការវិភាគនេះ ក្រុមយើងខ្ញុំបានប្រើវិធីសាស្រ្តក្នុងការប្រមូលទិន្នន័យតាមបែប ទិន្នន័យបឋម ឬប្រភពបឋម(Primary Source) ដែលយើងខ្ញុំនឹងធ្វើការសម្ភាសន៍ជាមួយអ្នករត់ម៉ូតូកង់បី(តុកតុក) ដើម្បីទទួលយកព័ត៌មាន និងទិន្នន័យដែលយើងខ្ញុំចង់បាន ដោយប្រើប្រាស់នូវកម្រងសំណួរដែលយើងខ្ញុំបានរៀបចំ(មើលឧបសម្ព័ន្ធ១)។ យើងខ្ញុំបានធ្វើការសម្ភាសន៍ក្នុងរាជធានីភ្នំពេញនៅកន្លែងមួយចំនួនៗដូចជា ផ្សារអូឡាំពិក ផ្សារច្បារអំពៅ ផ្សារបឹងត្របែក... ហើយយើងខ្ញុំជ្រើសរើសយកគំរូតាង(អ្នកត្រូវបានសម្ភាសន៍ គឺជាអ្នករត់ម៉ូតូកង់បីនៅក្នុងរាជធានីភ្នំពេញ) ចំនួន ២០០នាក់ រួចបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគ។

### ៣.១.១. ស្ថានភាពទូទៅនៃអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញ

#### ៣.១.១.១. ភេទ

តាមការសង្កេត និងផ្អែកលើទិន្នន័យដែលក្រុមយើងខ្ញុំបានចុះទៅសម្ភាសន៍ផ្ទាល់ជាមួយអ្នករត់ម៉ូតូកង់បីបានឲ្យដឹងថា អ្នកដែលប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី(តុកតុក) គឺ១០០% ជាបុរស ចំណែកស្ត្រីមិនមាននោះទេក្នុងចំណោមអ្នកដែលក្រុមយើងខ្ញុំបានចុះសម្ភាសន៍(មើលក្នុងឧបសម្ព័ន្ធ២) ប៉ុន្តែកន្លងមកមានអ្នកធ្លាប់ឃើញថាស្ត្រីក៏បានប្រកបមុខរបរមួយនេះដែរ ប៉ុន្តែមិនសូវមានច្រើនប៉ុន្មាននោះទេ។

### ៣.១.១.២. អាយុ

ដោយពឹងផ្អែកលើលទ្ធផលទទួលបានពីការចុះសម្ភាសន៍រួចមកយើងឃើញថា អ្នកផ្តល់ចម្លើយទាំងអស់មានអាយុក្នុងចន្លោះពី ១៨ ទៅ ៧៦ឆ្នាំ (គម្លាត ៥៨ឆ្នាំ) មានន័យថាអ្នកដែលមានអាយុច្រើនជាងគេ គឺ៧៦ឆ្នាំ ចំណែកឯអ្នកដែលមានអាយុតិចជាងគេ គឺ១៨ឆ្នាំ។ អាយុជាមធ្យមរបស់ពួកគាត់ គឺប្រហែលជា ៣៦ឆ្នាំ។ ក្នុងចំណោមពួកគាត់ទាំងអស់ភាគច្រើនមានអាយុក្នុងចន្លោះចាប់ពី ២១ ទៅ ៤០ឆ្នាំ ដែលមានចំនួនសរុបប្រមាណជា ១៤០នាក់ (ក្នុងនោះចន្លោះពី ២១ ទៅ ៣០ឆ្នាំមាន ៥៥នាក់ និងចន្លោះពី ៣១ ទៅ ៤០ឆ្នាំមានចំនួន ៨៥នាក់) ស្មើនឹង ៧០% នៃអ្នករត់ម៉ូតូកង់បីទាំងអស់ដែលបានផ្តល់ចម្លើយ។

ក្រាហ្វិកទី៣.១៖ អាយុ




*ប្រភព៖ ទិន្នន័យចម្បង*

លើសពីនេះទៀត យើងសង្កេតឃើញថា ចំនួនអ្នកដែលមានអាយុចន្លោះពី ៤១ ទៅ ៥០ឆ្នាំមានចំនួន ៣៦នាក់ ស្មើនឹង ១៨% ហើយចន្លោះពី ៥១ ទៅ ៦០ឆ្នាំមានត្រឹមតែ ១២នាក់ ស្មើនឹង ៦% ចំណែកអ្នកដែលមានអាយុចាប់ពី ៦១ឆ្នាំឡើងទៅមានចំនួន ២នាក់ ស្មើនឹង ១% និងអាយុចាប់ពី ២០ឆ្នាំចុះក្រោមមានចំនួន ១០នាក់ ស្មើនឹង ៥%។ នេះសបញ្ជាក់ឲ្យឃើញថា អ្នកដែលមានអាយុក្រោម ៥០ឆ្នាំមានសមត្ថភាពក្នុងការចេញទៅរកប្រាក់ចំណូលដើម្បីយកមកផ្គត់ផ្គង់ជីវភាពគ្រួសារ និងប្រឈមមុខទៅនឹងបញ្ហា ផ្សេងៗនៅក្នុងការប្រកបមុខរបរមួយនេះ។ ប៉ុន្តែនៅពេលដែលពួកគាត់មានអាយុលើសពី ៥០ឆ្នាំឡើងទៅ និងក្រោម ២០ឆ្នាំ ពួកគាត់ពុំសូវមានសមត្ថភាពក្នុងការចេញមករកប្រាក់ចំណូលជួយគ្រួសារនោះទេ។

### ៣.១.១.៣. រយៈពេលប្រកបមុខរបរ

ក្នុងចំណោមអ្នករត់ម៉ូតូកង់បីទាំងអស់ ដែលបានផ្ដល់ចម្លើយ គឺមានអ្នកដែលប្រកបមុខរបរនេះក្នុងចន្លោះចាប់ពី ១ ទៅ ៣ឆ្នាំ មានចំនួនច្រើនជាងគេ រហូតដល់ ១៥៥នាក់ ស្មើនឹង ៧៧,៥% នៃអ្នកផ្ដល់ចម្លើយទាំងអស់ ក្នុងនោះយើងឃើញថាអ្នកដែលទើបតែប្រកបមុខរបរនេះបានមួយឆ្នាំមានរហូតដល់ ៧៩នាក់ ស្មើនឹង ៣៩,៥% ចំពោះអ្នកដែលប្រកបមុខរបរនេះមិនទាន់បានមួយឆ្នាំមានចំនួន ២៦នាក់ ស្មើនឹង ១៣% នៃអ្នករត់ម៉ូតូកង់បីទាំងអស់ដែលបានផ្ដល់ចម្លើយ។ ចំណែកឯអ្នកដែលប្រកបមុខរបរក្នុងចន្លោះពី ៤ ទៅ ៦ឆ្នាំមានចំនួន ១២នាក់ ហើយអ្នកដែលប្រកបមុខរបរចាប់ពី ៧ឆ្នាំឡើងមានត្រឹមតែ ៧នាក់ ស្មើនឹង ៣,៥% តែប៉ុណ្ណោះ។ នេះសបញ្ជាក់ឲ្យឃើញថាមុខរបរនេះទើបតែកំពុងពេញនិយមយ៉ាងខ្លាំងនៅប៉ុន្មានឆ្នាំចុងក្រោយនេះ។

ក្រាហ្វិកទី៣.២៖ រយៈពេលប្រកបមុខរបររត់ម៉ូតូកង់បី




*ប្រភព៖ ទិន្នន័យចម្បង*

### ៣.១.១.៤. ស្ថានភាពគ្រួសារ

យោងតាមទិន្នន័យក្នុងក្រាហ្វិកទី៣.៣ បានបង្ហាញថា ភាគច្រើននៃអ្នកផ្ដល់ចម្លើយជាអ្នកដែលរៀបការរួចមានចំនួន ១៦២នាក់ ស្មើនឹង ៨១% នៃចំនួនទាំងអស់។ ខណៈពេលដែលបុរសពោះម៉ាយ (ត្រូវបានលែងលះ ឬស្លាប់) មានចំនួន ៦នាក់ ស្មើនឹង ៣% និងអ្នកនៅលីវមានចំនួន ៣២នាក់ ស្មើនឹង ១៦%។ ទាំងអស់នេះបានបង្ហាញថា អ្នកដែលមានគ្រួសារបានចេញមកប្រកបមុខរបរ ដើម្បីស្វែងរកប្រាក់ចំណូល ក្នុងការជួយផ្គត់ផ្គង់ជីវភាពគ្រួសារឲ្យមានភាពល្អប្រសើរឡើងមួយកម្រិតថែមទៀត មិនត្រឹមតែអ្នកដែលមានគ្រួសារនោះទេ យើងឃើញថាអ្នកនៅលីវក៏អាច

ជួយរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារបានផងដែរ តាមរយៈការប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី។

ក្រាហ្វិកទី៣.៣៖ ស្ថានភាពគ្រួសារ




*ប្រភព៖ ទិន្នន័យចម្បង*

### ៣.១.១.៥. ចំនួនអ្នកនៅក្នុងបន្ទុក

ក្នុងចំណោមគំរូតាងទាំងអស់ ចំនួនអ្នកនៅក្នុងបន្ទុកដែលមានសមាជិកច្រើនជាងគេ គឺមានត្រឹម ៨នាក់ ហើយចំនួនអ្នកនៅក្នុងបន្ទុកជាមធ្យមមានចំនួន ៤នាក់។

ក្រាហ្វិកទី៣.៤៖ ចំនួនសមាជិកក្នុងបន្ទុក




*ប្រភព៖ ទិន្នន័យចម្បង*

ជាក់ស្តែងនៅក្នុងក្រាបបង្ហាញយ៉ាងច្បាស់ថា ៥៨,៥% នៃគំរូតាង (១១៧នាក់ក្នុងចំណោម ២០០នាក់) រ៉ាប់រងលើអ្នកនៅក្នុងបន្ទុកចន្លោះពី ២ ទៅ ៤នាក់ ហើយ ២៨,៥% មានអ្នកនៅក្នុងបន្ទុកចន្លោះពី ៤ ទៅ ៦នាក់។ ចំណែកឯ ៦% មានចំនួនអ្នកនៅក្នុងបន្ទុកចន្លោះពី ៦ ទៅ ៨នាក់ ហើយ ៧%មានចំនួនអ្នកនៅក្នុងបន្ទុកពី ១ ទៅ ២នាក់។

ទោះបីជាសមាជិកក្នុងបន្ទុកគ្រួសារ ត្រូវបានពួកគាត់ជាអ្នករ៉ាប់រងចិញ្ចឹមក៏ពិតមែន ក៏ប៉ុន្តែសមាជិកមួយចំនួនក៏មានសមត្ថភាពក្នុងការជួយរកប្រាក់ចំណូលមកផ្គត់ផ្គង់ក្នុងគ្រួសារផងដែរ។ យោងតាមការផ្តល់ចម្លើយរបស់ពួកគាត់បានឲ្យដឹងថា អ្នកដែលរកចំណូលក្នុងគ្រួសារជាមធ្យមប្រហែលជា ២នាក់ ដែលមានចំនួនប្រមាណជា ៧៧នាក់ ស្មើនឹង ៣៨,៥% ចំពោះអ្នករត់ម៉ូតូកង់បីដែលជាអ្នករ៉ាប់រងលើសមាជិកគ្រួសារ ឬទទួលរ៉ាប់រងតែម្នាក់ឯងនោះមានប្រមាណជា ៥៥នាក់ ស្មើនឹង២៧,៥%។ អ្នករកចំណូលក្នុងគ្រួសារដែលមានគ្នា ៣នាក់ មានចំនួន ៤១នាក់ ស្មើនឹង ២០,៥% ហើយក្រៅពីនេះ ជាអ្នកដែលរកចំណូលក្នុងគ្រួសារមាន ៤នាក់ឡើងទៅ មានចំនួន ២៧នាក់ ស្មើនឹង១៣,៥%។

ក្រាហ្វិកទី៣.៥៖ អ្នករកចំណូលក្នុងគ្រួសារ




*ប្រភព៖ ទិន្នន័យចម្បង*

### ៣.១.១.៦. កម្រិតវប្បធម៌

ស្ថិតិបានបង្ហាញថា ចំនួនអ្នកដែលបានសិក្សាកម្រិតវិទ្យាល័យ(ថ្នាក់ទី១០-១២) មានច្រើនជាងគេ រហូតដល់ ៧៤នាក់ ស្មើនឹង ៣៧% ចំពោះអ្នកដែលបានសិក្សាកម្រិតអនុវិទ្យាល័យ(ថ្នាក់ទី៧-៩) និងបឋមសិក្សា(ថ្នាក់ទី១-៦) មានចំនួនប្រហាក់ប្រហែលគ្នា(៥៩នាក់

និង៥២នាក់ ស្មើនឹង ២៩,៥% និង២៦%រៀងគ្នា)។ ក្នុងចំណោមអ្នកទាំងនោះមានតែ ១៣នាក់ ៦,៥% ប៉ុណ្ណោះដែលសិក្សាថ្នាក់បរិញ្ញាបត្រ។ នេះបញ្ជាក់ថាអ្នកដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រខ្លះ មានសមត្ថភាពក្នុងការស្វែងរកការងារដែលល្អប្រសើរជាងនេះ ដើម្បីចិញ្ចឹមជីវិត និងគ្រួសារតាមជំនាញរបស់ពួកគាត់ ប៉ុន្តែពួកគាត់គិតថាមុខរបរមួយនេះមានភាពងាយស្រួលក្នុងការរកចំណូល និងមានឯករាជ្យភាពលើខ្លួនឯងទើបពួកគាត់សម្រេចចិត្តជ្រើសរើសមុខរបរនេះ។ ចំណែកអ្នកដែលបានសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ មានចំនួន ១នាក់(០,៥%) ស្មើនឹងអ្នកដែលមិនធ្លាប់បានសិក្សាសោះ។ បើនិយាយជារួម ពួកគាត់ស្ទើរតែទាំងអស់មានការអប់រំជាមធ្យមត្រឹមថ្នាក់ទី៩ ស្របតាមស្តង់ដាអប់រំនៃព្រះរាជាណាចក្រកម្ពុជា ដែលបានកំណត់ផងដែរ។

ក្រាហ្វិកទី៣.៦៖ កម្រិតវប្បធម៌




*ប្រភព៖ ទិន្នន័យចម្បង*

### ៣.១.១.៧. ស្រុកកំណើត

យោងតាមទិន្នន័យបានបង្ហាញថា អ្នកដែលប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី នៅក្នុងរាជធានីភ្នំពេញ ភាគច្រើនមានដើមកំណើតមកពីបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជាដែលមានប្រមាណជា ១៣៥នាក់ ស្មើនឹង ៦៧,៥%។ ចំណែកឯអ្នកដែលរស់នៅក្នុងរាជធានីភ្នំពេញ ក៏ចាប់យកមុខរបរនេះផងដែរ ដែលមានប្រមាណជា ៦៥នាក់ ស្មើនឹង ៣២,៥% នៃអ្នករត់ម៉ូតូកង់បីទាំងអស់ដែលបានផ្តល់ចម្លើយ។ ភាពជាក់ស្តែងយើងឃើញថា មុខរបរនេះមិនថាតែអ្នកដែលមានដើមកំណើតមកពីតាមបណ្តាខេត្តនានានោះទេ ដែលជាអ្នកប្រកបមុខរបររត់ម៉ូតូកង់បីនេះ សូម្បីតែអ្នកដែលរស់នៅក្នុងរាជធានីភ្នំពេញក៏ចាប់យកមុខរបរមួយនេះផងដែរ ក្នុងការរកប្រាក់ចំណូលដើម្បីយកមកផ្គត់ផ្គង់ និងចាយវាយតាមតម្រូវការក្នុងគ្រួសារប្រចាំថ្ងៃ។

ក្រាហ្វិកទី៣.៧៖ ស្រុកកំណើត




*ប្រភព៖ ទិន្នន័យចម្បង*

### ៣.១.២. កត្តាជំរុញឲ្យប្រកបមុខរបររត់ម៉ូតូកង់បី

ក្នុងចំណោមគំរូតាងទាំងអស់បានឲ្យដឹងថា កត្តាដែលជំរុញឲ្យពួកគាត់សម្រេចចិត្តប្រកបមុខរបររត់ម៉ូតូកង់បីនេះ ដែលជាមុខរបរមួយក្នុងចំណោមមុខរបរជាច្រើនទៀតក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសារតែពួកគាត់មានភាពលំបាកក្នុងការឈានជើងចូលទៅក្នុងទីផ្សារការងារសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងមានកត្តាមួយចំនួនទៀតដែលជំរុញឲ្យពួកគាត់សម្រេចចិត្តបែបនេះ។

ក្រាហ្វិកទី៣.៨៖ កត្តាជំរុញក្នុងការប្រកបមុខរបររត់ម៉ូតូកង់បី




*ប្រភព៖ ទិន្នន័យចម្បង*

យោងតាមទិន្នន័យ ប្រហែលជា ៣៥,៥% (៧១នាក់) នៃពួកគាត់គិតថាមុខរបរនេះងាយស្រួលក្នុងការរកប្រាក់ចំណូលសម្រាប់ទប់ទល់នឹងជីវភាពប្រចាំថ្ងៃក្នុងគ្រួសារ ព្រមទាំងអាចជួយក្នុងការរកប្រាក់ចំណូលក្នុងគ្រួសារផងដែរ។ ប្រហែលជា ២២% (៤៤នាក់) នៃពួកគាត់ គឺគ្មានជម្រើសផ្សេងពីមុខរបររត់ម៉ូតូកង់បី និងប្រហែលជា ១៨,៥% (៣៧នាក់) នៃពួកគាត់ជួបប្រទះនូវការខ្វះខាតចំណេះដឹង និងជំនាញផ្សេង ដែលធ្វើឲ្យពួកគាត់ពិបាកក្នុងការរកការងារធ្វើ។ ទន្ទឹមនឹងនេះ ប្រហែលជា ៦% (១២នាក់) នៃពួកគាត់បានផ្តល់ចម្លើយថា វាជាចំណង់ចំណូលចិត្តក្នុងការប្រកបមុខរបរនេះ ព្រោះពួកគាត់ចង់បានសិទ្ធិសេរីភាពលើខ្លួនឯង បើយើងមើលទៅលើការគេចវេសន៍ពីពន្ធ យើងឃើញថាមានប្រមាណជា ៥% (១០នាក់) តែប៉ុណ្ណោះ សរុបមក គឺពួកគាត់ទាំងអស់ពុំមានការយល់ដឹងអំពីបែបបទទាំងអស់នេះឡើយ។ ចំណែកឯ កត្តាផ្សេងៗទៀត បែរជាមានច្រើនជាងកត្តាចំណង់ចំណូលចិត្ត និងកត្តាគេចវេសន៍ពីពន្ធ ហើយកត្តាផ្សេងៗទាំងនោះមានដូចជា ការណែនាំពី មិត្តភក្តិ បងប្អូន ឬសាច់ញាតិ ជាដើម ដែលមានប្រមាណជា ១៣% (២៦នាក់)។

ក្រាហ្វិកទី៣.៩៖ ប្រភពនៃដើមទុនសម្រាប់ចាប់ផ្តើមអាជីវកម្ម




*ប្រភព៖ ទិន្នន័យចម្រុះ*

ម្យ៉ាងវិញទៀត វាអាចបណ្តាលមកពីកង្វះដើមទុនក្នុងការចាប់យកមុខរបរផ្សេង ដែលត្រូវប្រើប្រាស់ដើមទុនច្រើនក្នុងការចាប់ផ្តើម និងដំណើរការ។ ជាក់ស្តែង ក្រាហ្វិកទី៣.៩ បានបង្ហាញថា ប្រហែលជា ៣៣,៥% (៦៧នាក់) នៃអ្នករត់ម៉ូតូកង់បីទាំងអស់បានពឹងផ្អែកទាំងស្រុងទៅលើការកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ។ ប្រហែលជា ២៧% (៥៤នាក់) បានផ្តល់ចម្លើយថាពួកគាត់បានដើមទុនពីការសន្សំផ្ទាល់ខ្លួន។ ខណៈពេលដែលមានប្រមាណ ២២,៥% (៤៥នាក់) បាន

ដើមទុនមកពីការបង់រំលស់ និងប្រហែលជា ១៦% (៣២នាក់) នៃពួកគាត់បានដើមទុនមកពីការខ្ចីពីសាច់ញាតិបងប្អូន ចំណែកប្រភពដើមទុនដែលទទួលបានពីជំនួយរដ្ឋាភិបាលក្នុងការចាប់ផ្តើមមុខរបរ គឺមិនមាននោះទេ។ ការណ៍នេះសបញ្ជាក់ឲ្យឃើញថា រាជរដ្ឋាភិបាលពុំមានការយកចិត្តទុកដាក់ និងជួយអន្តរាគមន៍លើបញ្ហាដើមទុនក្នុងការចាប់ផ្តើមអាជីវកម្ម ឬមុខរបរក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនោះទេ។

### ៣.១.៣. បញ្ហាប្រឈមនានាដែលអ្នករត់ម៉ូតូកង់បីជួបប្រទះ

កំឡុងពេលប្រមូលព័ត៌មាន ដែលទាក់ទងនឹងបញ្ហាប្រឈមរបស់អ្នករត់ម៉ូតូកង់បី ពួកគាត់បានផ្តល់ចម្លើយ ដែលទាក់ទងនឹងបញ្ហាប្រឈមរបស់ពួកគាត់ក្នុងការប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បីនេះថា បញ្ហាប្រឈមរបស់ពួកគាត់ គឺមានការជួបប្រទះទាំងកំឡុងពេលចាប់ផ្តើម និងកំឡុងពេលដំណើរការ។ លទ្ធផលដែលទទួលបានត្រូវបានបង្ហាញនៅក្នុងក្រាហ្វិកទី៣.១០ និង ៣.១១ ខាងក្រោមនេះ។

ក្រាហ្វិកទី៣.១០៖ បញ្ហាប្រឈមពេលចាប់ផ្តើមប្រកបមុខរបររត់ម៉ូតូកង់បី




*ប្រភព៖ ទិន្នន័យចម្បង*

ទិន្នន័យក្នុងក្រាហ្វិកទី៣.១០ បានបង្ហាញថា ក្នុងពេលចាប់ផ្តើមប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី ប្រហែលជា ៣៦% នៃពួកគាត់(៧២នាក់) បានជួបប្រទះនូវបញ្ហាខ្វះខាតដើមទុន ទោះបីជាមុខរបរមួយនេះមិនតម្រូវឲ្យមានដើមទុនច្រើនក៏ពិតមែន ក៏ពួកគាត់នៅតែមានការខ្វះខាតដើមទុនដដែល ព្រោះពួកគាត់ភាគច្រើនជាអ្នកមកពីបណ្តាខេត្តនានា(ក្រាហ្វិកទី៣.៧) ដើម្បីមកប្រកបមុខរបររកប្រាក់ចំណូលក្នុងការជួយផ្គត់ផ្គង់គ្រួសារដែលមានការលំបាក។ ពួកគាត់ទាំងអស់មានភាព

ប្រហាក់ប្រហែលគ្នាត្រង់បញ្ហាគ្មានជំនាញ និងគ្មានបទពិសោធន៍(២៤នាក់ និង២៣នាក់ ស្មើនឹង ១២% និង១១,៥%រៀងគ្នា) ក្នុងការទាក់ទងអតិថិជន ឬភ្ញៀវ ឲ្យមកប្រើប្រាស់នូវសេវាដឹកជញ្ជូនរបស់ពួកគាត់ និងមួយផ្នែកទៀត គ្មានជំនាញក្នុងការថែរក្សាអតិថិជន ហើយគ្មានបទពិសោធន៍ក្នុងការប្រើប្រាស់ម៉ូតូកង់បីជាដើម។ ប្រហែលជា ១៦% នៃពួកគាត់ពុំសូវមានតម្រូវការ ចំណែកបញ្ហាប្រឈមផ្សេងទៀតយើងឃើញថាមានប្រមាណជា ២៤,៥% នៃអ្នករត់ម៉ូតូកង់បីទាំងអស់ដែលបានផ្តល់ជាព័ត៌មាន។

ក្រាហ្វិកទី៣.១១៖ បញ្ហាប្រឈមពេលកំពុងប្រកបមុខរបររត់ម៉ូតូកង់បី




*ប្រភព៖ ទិន្នន័យចម្បង*

ក្រៅពីបញ្ហាដែលពួកគាត់ជួបប្រទះនៅពេលចាប់ផ្តើមមុខរបរជាអ្នករត់ម៉ូតូកង់បី ពួកគាត់ក៏ជួបប្រទះនូវបញ្ហាផ្សេងៗទៀតក្នុងកំឡុងពេលប្រកបមុខរបរនេះផងដែរ។ ជាក់ស្តែង ក្នុងក្រាហ្វិកទី៣.១១ បានបង្ហាញយ៉ាងច្បាស់ថា បញ្ហាចម្បងដែលពួកគាត់ជួបប្រទះ គឺបញ្ហាពុំសូវមានអតិថិជន ឬភ្ញៀវប្រើប្រាស់នូវសេវាដឹកជញ្ជូនខ្នាតតូចមួយនេះប្រហែលជា ១១១នាក់ ស្មើនឹង ៥៥,៥% ដែលពួកគាត់ពិបាកក្នុងការរកអតិថិជន បានធ្វើឲ្យពួកគាត់រកប្រាក់ចំណូលពុំសូវបាន ហើយមូលហេតុដែលពុំសូវមានអតិថិជន គឺបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលធ្វើឲ្យរាំងស្ទះ ក្នុងការធ្វើដំណើររបស់ប្រជាពលរដ្ឋ ទើបធ្វើឲ្យមិនសូវមានភ្ញៀវ។ ប្រហែលជា ២២,៥%(៤៥នាក់) បានផ្តល់ចម្លើយថា ឥឡូវនេះអ្នកផ្គត់ផ្គង់សេវាបែបនេះមានច្រើនពេក ដែលពួកគាត់ត្រូវធ្វើការប្រកួតប្រជែងគ្នា ដើម្បីទទួលបានភ្ញៀវ(ដែលពួកគាត់ត្រូវចែកនូវប្រាក់ចំណូល ឬអតិថិជនទៅឲ្យគ្នា) ហើយប្រហែជា ៨% (១៦នាក់) នៃពួកគាត់បានជួបប្រទះក្នុងកំឡុងពេលប្រកបមុខរបរជាអ្នករត់

ម៉ូតូកង់បី គឺម៉ូតូកង់បីខូចដែលពួកគាត់បានលើកឡើងថា គ្រឿងបន្លាស់របស់វាមានតម្លៃថ្លៃ ដូច្នេះហើយបានជាពេលខូចម្តងៗ គឺត្រូវចំណាយអស់ច្រើនទៅលើគ្រឿងបន្លាស់នេះ។ ចំណែកបញ្ហាប្រឈមដែលកើតពីអាកាសធាតុ ស្ទះចរាចរណ៍ ឧបទ្ទវហេតុចរាចរណ៍ និងបញ្ហាផ្សេងៗទៀត មានប្រមាណជា ១៤%តែប៉ុណ្ណោះនៃបញ្ហាប្រឈមរបស់អ្នករត់ម៉ូតូកង់បីដែលបានធ្វើការសម្ភាសន៍។

### ៣.១.៤. ឥទ្ធិពលចំពោះគ្រួសារ

ខណៈពេលដែលពួកគាត់ចេញទៅប្រកបមុខរបរនៅខាងក្រៅផ្ទះ ពួកគាត់ក៏បានបន្សល់នូវឥទ្ធិពលទាំងវិជ្ជមាន និងអវិជ្ជមានដល់គ្រួសារ។ ទិន្នន័យខាងក្រោមនេះនឹងបង្ហាញឲ្យយើងបានដឹងអំពីឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានដល់គ្រួសារតាមរយៈមុខរបររត់ម៉ូតូកង់បី។ តាមក្រាបអវិជ្ជមានបានបង្ហាញថា ប្រហែលជា ៣០,៥% នៃពួកគាត់ (៦១នាក់) ពុំសូវមានពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារដោយសារពួកគាត់ចេញពីផ្ទះទៅរកប្រាក់ចំណូលតាំងពីព្រលឹមទល់ព្រលប់។ ពួកគាត់ពុំសូវមានពេលវេលាតាមដានការសិក្សាកូនមានចំនួន ១៨នាក់(៩%) ស្មើនឹងអ្នកដែលខ្វះភាពកក់ក្តៅផ្តល់ដល់កូនៗរបស់ពួកគាត់។

ក្រាហ្វិកទី៣.១២៖ ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ




*ប្រភព៖ ទិន្នន័យចម្បង*

ម្យ៉ាងវិញទៀត ពួកគាត់ពុំសូវមានពេលវេលាសម្រាកឲ្យបានគ្រប់គ្រាន់ ដែលជាហេតុធ្វើឲ្យសុខភាពរបស់ពួកគាត់ចុះខ្សោយ ដោយសារតែខិតខំរកប្រាក់ចំណូលខ្លាំងពេក ដែលមិនបានគិតដល់ការសម្រាក និងថែទាំសុខភាពរបស់ខ្លួន ដែលមានប្រមាណជា ១៤% ស្មើនឹង ២៨នាក់ និងមានឥទ្ធិពលផ្សេងទៀតដែលមានរហូតដល់ ២៩% នៃអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញទាំងអស់ដែលបានផ្តល់ជាចម្លើយ។

បើយើងក្រឡេកមើលអំពីឥទ្ធិពលវិជ្ជមានវិញ ទិន្នន័យបានបង្ហាញថា ការប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី បានចូលរួមក្នុងការចំណាយប្រចាំថ្ងៃក្នុងគ្រួសារមានដូចជា ថ្លៃម្ហូបអាហារ សម្ភារៈប្រើប្រាស់ និងចំណាយផ្សេងៗទៀតក្នុងគ្រួសារ ដែលមានរហូតដល់៨០,៥% (១៦១នាក់) ស្របពេលដែលពួកគាត់ជួយសម្រួលដល់ការជូនប្រពន្ធទៅធ្វើការ ឬជូនកូនទៅសាលារៀន រួមនឹងឥទ្ធិពលវិជ្ជមានដទៃទៀតមានត្រឹមតែ ១៩,៥% (៣៩នាក់) តែប៉ុណ្ណោះ។ ទាំងនេះសបញ្ជាក់ឲ្យឃើញថាការប្រកបមុខរបររត់ម៉ូតូកង់បី គឺពិតជាអាចជួយសម្រាលបន្ទុកក្នុងការចំណាយប្រចាំថ្ងៃក្នុងគ្រួសារបានពិតមែន។

ក្រាហ្វិកទី៣.១៣៖ ឥទ្ធិពលវិជ្ជមានចំពោះគ្រួសារ




*ប្រភព៖ ទិន្នន័យចម្បង*

## ៣.១.៥. ការលើកកម្ពស់ជីវភាពគ្រួសាររបស់អ្នករត់ម៉ូតូកង់បីតាមរយៈប្រាក់ចំណូល

### ៣.១.៥.១. ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ

យោងតាមតារាងទី៣.១ បានបង្ហាញថា ក្នុងចំណោមគំរូតាងទាំង ២០០នាក់ជាអ្នករត់ម៉ូតូកង់បី(តុកតុក) ដែលបានចូលរួមផ្តល់ជាព័ត៌មាន អាចរកប្រាក់ចំណូលបានជាមធ្យមប្រចាំថ្ងៃគឺប្រមាណជា ៥៥.០០០រៀលក្នុងមួយថ្ងៃ។ ចំណែកឯប្រាក់ចំណូលដែលពួកគាត់រកបានខ្ពស់បំផុតមានរហូតដល់ ១២០.០០០រៀល និងប្រាក់ចំណូលដែលរកបានទាបបំផុតមានត្រឹមតែ ១០.០០០រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ។

តារាងទី៣.១៖ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូកង់បី

| | |
|---|---|
| គំរូតាង | ២០០នាក់ |
| គម្លាតស្តង់ដា | ១៨.៥៤០,៩៤ |
| មធ្យម | ៥៥.៩៥០រៀល |
| អតិបរមា | ១២០.០០០រៀល |
| អប្បបរមា | ១០.០០០រៀល |
| សរុប | ១១.០៩០.០០០រៀល |

*ប្រភព៖ ទិន្នន័យចម្បង*

បើយើងក្រឡេកទៅមើលទិន្នន័យនៅក្នុងក្រាហ្វិកទី៣.១៤ យើងឃើញថា អ្នករត់ម៉ូតូកង់បីប្រហែលជា ៦៣% អាចរកប្រាក់ចំណូលបានក្នុងចន្លោះពី ៣០.០០០ ទៅ ៦០.០០០រៀលក្នុងមួយថ្ងៃ ប្រហែលជា ២៣% អាចរកប្រាក់ចំណូលបានក្នុងចន្លោះពី ៦០.០០០ ទៅ ៩០.០០០រៀលក្នុងមួយថ្ងៃ ហើយប្រហែលជា ១០% អាចរកប្រាក់ចំណូលបានក្នុងចន្លោះពី ១០.០០០ ទៅ ៣០.០០០រៀលក្នុងមួយថ្ងៃ ខណៈពេលដែលអ្នកដែលអាចរកប្រាក់ចំណូលបានចន្លោះពី ៩០.០០០ ទៅ ១២០.០០០រៀលក្នុងមួយថ្ងៃមានត្រឹមតែ ៤% តែប៉ុណ្ណោះ។

ក្រាហ្វិកទី៣.១៤៖ ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ




*ប្រភព៖ ទិន្នន័យចម្បង*

ចំណែកឯអ្នកដែលអាចរកប្រាក់ចំណូលលើសពី ១២០.០០០រៀលក្នុងមួយថ្ងៃមិនមាននោះទេ បើតាមការផ្តល់ចម្លើយរបស់អ្នករត់ម៉ូតូកង់បីទាំងអស់។

### ៣.១.៥.២. ប្រាក់ចំណាយជាមធ្យមប្រចាំថ្ងៃ

តាមទិន្នន័យដែលទទួលបានពីការផ្តល់ចម្លើយរបស់អ្នករត់ម៉ូតូកង់បី(តុកតុក) ទាំងអស់បានបង្ហាញថា ជារៀងរាល់ថ្ងៃប្រហែល ៣៦% នៃអ្នករត់ម៉ូតូកង់បីទាំងអស់ត្រូវចំណាយលើជីវភាពប្រចាំថ្ងៃដូចជា ថ្លៃម្ហូបអាហារ ចាក់ហ្គាស និងកូនរៀនជាដើម អស់ប្រហែល ៤០.០០០រៀល និងប្រហែល ២៧% ត្រូវចំណាយអស់ប្រហែល ៣០.០០០រៀលក្នុងមួយថ្ងៃ។ បើនិយាយជារួមប្រហែល ៥៥% នៃពួកគាត់(១១០នាក់) ត្រូវចំណាយក្នុងចន្លោះពី ១០.០០០ ទៅ ៣០.០០០រៀលក្នុងមួយថ្ងៃ។ ចំណែកឯអ្នកដែលចំណាយចន្លោះពី ៣០.០០០ ទៅ ៦០.០០០រៀល មានប្រមាណ ៤៥% នៃពួកគាត់(៩០នាក់) ដែលត្រូវចំណាយជាមធ្យមប្រចាំថ្ងៃ (មើលក្នុងឧបសម្ព័ន្ធ២)។

យោងតាមតារាងទី៣.២ បង្ហាញថា អ្នករត់ម៉ូតូកង់បីត្រូវចំណាយជាមធ្យមអស់ប្រហែល ៣០.០០០រៀល (មធ្យម = ៣២.៥៣០រៀល) ក្នុងមួយថ្ងៃ។

តារាងទី៣.២៖ ប្រាក់ចំណាយជាមធ្យមប្រចាំថ្ងៃរបស់អ្នករត់ម៉ូតូកង់បី

| | |
|---|---|
| គម្លាតស្តង់ដា | ១០.១១៣,៨៨ |
| មធ្យម | ៣២.៥៣០រៀល |
| អតិបរមា | ៦០.០០០រៀល |
| អប្បបរមា | ១០.០០០រៀល |

*ប្រភព៖ ទិន្នន័យចម្បង*

ជារួមពួកគាត់ចំណាយជាប្រចាំថ្ងៃអស់ប្រហែលចន្លោះពី ២០.០០០ ទៅ ៦០.០០០រៀលក្នុងកម្រិតខុសគ្នាបន្តិចបន្តួចទៅតាមស្ថានភាពជាក់ស្តែងរបស់ពួកគាត់។

### ៣.១.៥.៣. ប្រាក់សន្សំជាមធ្យមប្រចាំខែ

បន្ទាប់ពីការចំណាយប្រចាំថ្ងៃ និងទូទាត់នូវការចំណាយរាល់ខែដូចជា ថ្លៃផ្ទះជួល (បើមាន) ថ្លៃទឹក ភ្លើង ពិធីមង្គលការ បុណ្យ ជាដើមរួចមក ឃើញថាប្រហែល ៧៥,៥% នៃអ្នករត់ម៉ូតូកង់បី (១៥១នាក់ក្នុងចំណោម ២០០នាក់) មានលទ្ធភាពក្នុងការសន្សំថវិកាសម្រាប់ទុកប្រើប្រាស់នៅក្នុងគ្រាចាំបាច់ទៀតផង។ យើងឃើញថា ប្រមាណជា ៤២% នៃពួកគាត់(៨៤នាក់) អាចសន្សំប្រាក់ជាមធ្យមក្នុងមួយខែចន្លោះពី ៣០.០០០ ទៅ ៤០០.០០០រៀល ប្រមាណជា ២៣% នៃពួកគាត់(៤៦នាក់) អាចសន្សំប្រាក់ជាមធ្យមប្រចាំខែចន្លោះពី ៤០០.០០០រៀល ទៅ ៨០០.០០០រៀល។ ចំណែកឯអ្នកដែលរត់ម៉ូតូកង់បីអាចសន្សំប្រាក់បានជាមធ្យមក្នុងមួយខែចាប់ពី ៨០០.០០០រៀលឡើងទៅមានត្រឹមតែ ១០,៥% ស្មើនឹង ២១នាក់តែប៉ុណ្ណោះ។ ចំពោះអ្នករត់ម៉ូតូកង់បីចំនួន ៤៩នាក់

ស្មើនឹង ២៤,៥% ដែលពុំមានប្រាក់សន្សំ ព្រោះពួកគាត់ត្រូវបានចំណាយក្នុងគ្រួសារ ម្យ៉ាងវិញទៀតក្នុងពេលបច្ចុប្បន្ននេះ ពួកគាត់ពុំសូវរកប្រាក់ចំណូលបាននោះទេ ដោយសារតែមានការរំខានពីជំងឺកូវីដ-១៩(មើលក្នុងឧបសម្ព័ន្ធ២)។

យោងតាមតារាងទី៣.៣ បង្ហាញថា អ្នករត់ម៉ូតូកង់បីអាចធ្វើការសន្សំបានជាមធ្យមប្រមាណជា ៤០០.០០០រៀលក្នុងមួយខែ ហើយប្រាក់សន្សំអតិបរមារបស់អ្នករត់ម៉ូតូកង់បីខ្លះមានរហូតដល់ ១.៨០០.០០០រៀល។

តារាងទី៣.៣៖ ប្រាក់សន្សំជាមធ្យមប្រចាំខែរបស់អ្នករត់ម៉ូតូកង់បី

| | |
|---|---|
| គម្លាតស្តង់ដា | ៣៧៤.៧១៧,៨២ |
| មធ្យម | ៤២៩.៦៥០រៀល |
| អតិបរមា | ១.៨០០.០០០រៀល |
| អប្បបរមា | ០០រៀល |

*ប្រភព៖ ទិន្នន័យចម្បង*

ជារួម ពួកគាត់មានលទ្ធភាពសន្សំប្រាក់បានយ៉ាងហោចណាស់ក្នុងចន្លោះពី ២០០.០០០ ទៅ ៤០០.០០០រៀលក្នុងមួយខែ ដើម្បីប្រើប្រាស់នៅពេលមានបញ្ហាផ្សេងៗក្នុងគ្រួសារ។ ទាំងអស់នេះសបញ្ជាក់ឲ្យឃើញថា ការប្រកបមុខរបររត់ម៉ូតូកង់បី(តុកតុក) មិនត្រឹមតែចូលរួមចំណែកក្នុងការចំណាយនៅក្នុងគ្រួសារនោះទេ ថែមទាំងអាចចូលរួមក្នុងការបង្កើនប្រាក់ចំណូលក្នុងគ្រួសារថែមទៀតផង។ ជាពិសេសនៅអាចមានប្រាក់សន្សំទុកបម្រុងសម្រាប់ប្រើការក្នុងគ្រួសារនៅពេលចាំបាច់ ឬប្រើក្នុងគ្រាណាមួយបានទៀតផង។ សរុបមក មុខរបរជាអ្នករត់ម៉ូតូកង់បីពិតជាអាចចូលរួមក្នុងការលើកកម្ពស់ជីវភាពគ្រួសារបានយ៉ាងពិតមែន។

## ៣.២. ការវិភាគ SWOT

យោងតាមការចុះយកទិន្នន័យផ្ទាល់ជាមួយអ្នករត់ម៉ូតូកង់បី(តុកតុក) ក្នុងរាជធានីភ្នំពេញ យើងឃើញថា មុខរបរនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រភេទនេះ មានទាំងចំណុចខ្លាំង និងចំណុចខ្សោយ លើសពីនេះអ្នកដែលប្រកបមុខរបរនេះក៏ទទួលបានការគំរាមកំហែងមួយចំនួនពីសង្គម ក៏ដូចជាមជ្ឈដ្ឋានជុំវិញ ប៉ុន្តែទន្ទឹមនឹងការគំរាមកំហែង ពួកគាត់ក៏អាចទទួលបានឱកាសមួយចំនួនពីការប្រកបមុខរបរនេះផងដែរ។ ជាក់ស្តែង ទិន្នន័យដែលទទួលបានពីអ្នករត់ម៉ូតូកង់បីរួមមាន៖

### ៣.២.១. ចំណុចខ្លាំង

- ពួកគាត់ក្លាយជាអ្នករកចំណូលមួយរូបក្នុងគ្រួសារ តាមរយៈការប្រកបមុខរបរសុចរិត
- ពួកគាត់បានរួមចំណែកក្នុងការលើកកម្ពស់ជីវភាពគ្រួសារឲ្យមានភាពប្រសើរឡើង តាមរយៈប្រាក់សន្សំប្រចាំខែ
- ពួកគាត់ជួយសម្រួលការចំណាយនៅក្នុងបន្ទុកគ្រួសារដូចជា ការចំណាយលើការសិក្សារបស់កូន ការចំណាយលើម្ហូបអាហារប្រចាំថ្ងៃ ការចំណាយលើថ្លៃជួលផ្ទះ (បើមាន) ទឹកភ្លើង និងការចំណាយផ្សេងៗ
- ពួកគាត់ទទួលបានសិទ្ធិសេរីភាព និងឯករាជ្យភាពក្នុងការចេញទៅប្រកបមុខរបរ
- ជូនប្រពន្ធទៅធ្វើការ ឬជូនកូនទៅសាលារៀន។

### ៣.២.២. ចំណុចខ្សោយ

- ពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារ
- អាចប្រឈមនឹងគ្រោះថ្នាក់ចរាចរណ៍គ្រប់ពេល
- ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការតាមដានការសិក្សារបស់កូន។

### ៣.២.៣. ឱកាស

- អាចស្គាល់ និងមានទំនាក់ទំនងបន្ថែមជាមួយអ្នកដទៃ
- អាចបង្ហាញពីសមត្ថភាព និងសក្តានុពលពិតប្រាកដរបស់ខ្លួនដល់សមាជិកក្នុងគ្រួសារ
- អាចធ្វើឲ្យគ្រួសារមានជីវភាពប្រសើរជាងមុន។

### ៣.២.៤. ការគំរាមកំហែង

- ជំងឺកូវីដ-១៩ បានធ្វើឲ្យពួកគាត់បាត់បង់ប្រាក់ចំណូល
- ការកកស្ទះចរាចរណ៍
- ការប្រកួតប្រជែងពីសំណាក់អ្នកប្រកបមុខរបរដូចគ្នា
- ការប្រែប្រួលមិនទៀងទាត់នៃអាកាសធាតុ។

## ៣.៣. លទ្ធផលស្រាវជ្រាវ

❖ **ចំណុចវិជ្ជមាន**

- នៅពេលដែលពួកគាត់បានប្រកបមុខរបរនេះ ធ្វើឲ្យជីវភាពរបស់ពួកគាត់មានភាពប្រសើរជាងមុន

- មានថវិកាគ្រប់គ្រាន់ក្នុងការចំណាយប្រចាំថ្ងៃក្នុងគ្រួសារ
- អាចធ្វើឲ្យពួកគាត់មានប្រាក់សន្សំប្រើប្រាស់ក្នុងពេលអនាគត
- អាចឲ្យកូនៗរបស់ពួកគាត់បន្តការសិក្សាដល់ថ្នាក់ខ្ពស់។

❖ **ចំណុចអវិជ្ជមាន**

- ពុំបានផ្តល់ភាពកក់ក្តៅពេលលេញដល់កូនៗ និងសមាជិកក្នុងគ្រួសារ ដោយសារតែពួកគាត់ខ្លះ ធ្វើការចំណាកស្រុកតែម្នាក់ឯង ដោយពុំបានយកប្រពន្ធកូនមកជាមួយនោះទេ
- ពួកគាត់អាចប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេលកំពុងបើកបរ
- សុខភាពខ្សោយ។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើ ស្ថានភាព ការប្រមូលទិន្នន័យ និងវិភាគទិន្នន័យដែលបានចុះសម្ភាសន៍ដោយផ្ទាល់ ជាមួយប្រជាពលរដ្ឋដែលជាអ្នកប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បីក្នុងរាជធានីភ្នំពេញរួចមក យើងសង្កេតឃើញថា មុខរបរមួយនេះកំពុងតែមានការគាំទ្រយ៉ាងច្រើនពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ មិនថាតែប្រជាពលរដ្ឋខ្មែរនោះទេ សូម្បីតែជនបរទេសដែលមកធ្វើការ ឬកម្សាន្តក្នុងរាជធានីភ្នំពេញក៏បានប្រើសេវាដឹកជញ្ជូនតាមម៉ូតូកង់បីផងដែរ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ ពួកគាត់បានត្អូញត្អែរថា ពួកគាត់កំពុងតែជួបការលំបាកក្នុងការរកប្រាក់ចំណូលដោយសារតែបច្ចុប្បន្ននេះពុំសូវមានភ្ញៀវ ដែលបណ្តាលមកពីការរាតត្បាតជាសកលនៃមេរោគកូវីដ-១៩ ដែលបានរកឃើញដំបូងគេនៅក្នុងប្រទេសចិន ហើយបានរីករាលដាលមកដល់ប្រទេសកម្ពុជានៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០។

ផ្អែកតាមទិន្នន័យ ដែលទទួលបានពីការចុះស្រង់មតិផ្ទាល់ពីអ្នកប្រកបមុខរបរជាអ្នករត់ម៉ូតូកង់បី(ជំពូកទី៣) យើងឃើញថា ចំពោះប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ ពួកគាត់អាចរកចំណូលបានជាមធ្យមក្នុងចន្លោះពី ១០.០០០រៀល ទៅ ៦០.០០០រៀលជារៀងរាល់ថ្ងៃ។ ប្រាក់ចំណូលដែលពួកគាត់ទទួលបានត្រូវយកមកទប់ទល់នឹងការចំណាយនៅក្នុងគ្រួសារ ដែលការចំណាយទាំងអស់នោះជាមធ្យមចន្លោះពី ២០.០០០រៀល ទៅ ៥០.០០០រៀលក្នុងមួយថ្ងៃ បន្ទាប់ពីការចំណាយរួចមកពួកគាត់នៅអាចធ្វើការសន្សំបានទៀតផង ទោះបីជាការចាប់ផ្តើមប្រកបមុខរបរនេះ (ទិញម៉ូតូកង់បី) ទទួលបានដើមទុនពីប្រភពផ្សេងៗគ្នាក៏ដោយ ដែលអ្នកខ្លះចាប់ផ្តើមដោយប្រាក់សន្សំផ្ទាល់ខ្លួន អ្នកខ្លះទៀតបានមកពីការបង់រំលស់ និងកម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារដែលត្រូវសងត្រឡប់ទៅវិញជារៀងរាល់ខែយ៉ាងនេះក្តី ក៏ពួកគាត់នៅតែអាចសន្សំបានជាមធ្យមចន្លោះពី ២០០.០០០រៀល ទៅ ៤០០.០០០រៀលក្នុងមួយខែ។ ប្រាក់សន្សំទាំងអស់នេះពួកគាត់នឹងអាចយកទៅប្រើប្រាស់ទៅតាមគោលបំណង ឬគម្រោងថ្ងៃអនាគតរបស់ពួកគាត់ ម្យ៉ាងវិញទៀតអាចប្រើប្រាស់ក្នុងការចំណាយចំបាច់ណាមួយដូចជា ជំងឺដង្កាត់ គ្រោះថ្នាក់ផ្សេងៗ ឬហេតុការណ៍ដែលកើតមានឡើងនៅថ្ងៃខាងមុខដោយមិនអាចដឹងមុន។ល។ ពួកគាត់ទាំងអស់គ្នាមិនត្រឹមតែអាចរកប្រាក់ចំណូល និងប្រាក់សន្សំ ដើម្បីផ្គត់ផ្គង់ និងលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់ប៉ុណ្ណោះទេ ថែមទាំងអាចបង្កើននូវទំនាក់ទំនងជាមួយមនុស្សនៅជុំវិញខ្លួនក្នុងសង្គម ស្គាល់ពីតម្លៃខ្លួនឯង តម្លៃការងារដែលខ្លួនកំពុងធ្វើ និងឱកាសផ្សេងៗដែលអាចឲ្យពួកគាត់អភិវឌ្ឍន៍ខ្លួន និង

គ្រួសារ។ នៅពីក្រោយនៃប្រាក់ចំណូលរបស់ពួកគាត់ក៏មានចំណុចអវិជ្ជមានមួយចំនួនផងដែរ ក្នុងនោះមានដូចជា ពួកគាត់ពុំសូវមានពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារ និងពុំសូវមានពេលវេលាតាមដានការសិក្សាកូនៗរបស់ពួកគាត់ជាដើម។

សរុបសេចក្តីមក ការប្រកបមុខរបររត់ម៉ូតូកង់បីដែលជាការងារមួយប្រភេទក្នុងចំណោមការងារជាច្រើនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់នូវកម្រិតជីវភាពគ្រួសាររបស់ពួកគាត់ឲ្យមានការរីកចម្រើនពិតប្រាកដមែន ព្រោះពួកគាត់បានខិតខំប្រឹងប្រែង និងអត់ធ្មត់គ្រប់រូបភាពក្នុងការរកប្រាក់ចំណូលយកមកផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគាត់ ទោះបីជាពួកគាត់បន្សល់នូវឥទ្ធិពលអវិជ្ជមានតិចតួចក៏ដោយ។

## ២. អនុសាសន៍

ការប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធអាចជួយសម្រួល និងសម្រាលដល់ការរស់នៅ ក៏ដូចជាអាចលើកកម្ពស់ជីវភាពគ្រួសារបានមួយកម្រិត។ បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក យើងខ្ញុំឃើញមានចំណុចខ្វះខាត និងចំណុចអវិជ្ជមានមួយចំនួនដែលប៉ះពាល់ដល់មុខរបររត់ម៉ូតូកង់បី។ ដោយឃើញដូច្នេះហើយ យើងខ្ញុំសូមចូលរួមចំណែកផ្តល់ជាអនុសាសន៍ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- រដ្ឋគួរតែផ្សព្វផ្សាយឲ្យបានទូលំទូលាយពីបញ្ហាដែលពួកគាត់បានចត ឬធ្វើដំណើរមិនគោរពច្បាប់ចរាចរណ៍ ឬចតគ្មានសណ្តាប់ធ្នាប់ ដើម្បីឲ្យពួកគាត់បានយល់ដឹង និងព្យាយាមបញ្ចៀសពីឥទ្ធិពលអវិជ្ជមានដែលពួកគាត់បានបង្កឡើង
- ក្រុមហ៊ុនដែលបម្រើការសេវាដឹកជញ្ជូនតាមប្រព័ន្ធអ៊ីនធឺណិតទាំងអស់ ដែលពួកគាត់បានភ្ជាប់មានដូចជា PassApp Grab និងTADA ជាដើម គួរតែកុំយកថ្លៃសេវាខ្ពស់ពេក ឬបញ្ចុះតម្លៃសម្រាប់ការធ្វើដំណើរខ្លាំងពេក ដែលនាំឲ្យពួកគាត់ទទួលបានប្រាក់ចំណូលតិច
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារ គួរតែបញ្ចុះអត្រាការប្រាក់ក្នុងការលើកទឹកចិត្តឲ្យមានការប្រកបអាជីវកម្មក្រៅប្រព័ន្ធ ពិសេសអ្នករត់ម៉ូតូកង់បី ដើម្បីលើកកម្ពស់សេដ្ឋកិច្ចគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិ។
- អតិថិជន ឬភ្ញៀវដែលបានកក់ម៉ូតូកង់បី(តាមប្រព័ន្ធអ៊ីនធឺណិត) ក្នុងការធ្វើដំណើរទាំងអស់គួរតែចេញមករងចាំឲ្យបានមុខពេលដែលពួកគាត់មកដល់ ដើម្បីងាយស្រួល និងកុំឲ្យស្ទះចរាចរដល់អ្នកធ្វើដំណើរផ្សេងទៀត

ម្យ៉ាងវិញទៀត សូមសំណូមពរដល់អតិថិជន ឬភ្ញៀវមេត្តាអធ្យាស្រ័យ ចំពោះការចូលទៅទទួលមិនបានដល់ទីតាំង ព្រោះពេលខ្លះទីតាំងដែលត្រូវចតចាំទទួល ឬឈប់ជាកន្លែងដែលត្រូវបានគេហាមចត។ ជាពិសេស សូមសំណូមពរដល់អ្នករត់ម៉ូតូកង់បីទាំងអស់ សូមធ្វើការបើកបរដោយក្រមសីលធម៌ ចេះអធ្យាស្រ័យគ្នាទៅវិញទៅមក និងចូលរួមគោរពច្បាប់ចរាចរណ៍ដែលរដ្ឋាភិបាលបានដាក់ចេញទាំងអស់គ្នា។

# ឯកសារយោង

# ឯកសារយោង

## ❖ ឯកសារយោងជាភាសាខ្មែរ


ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ. ២០១៩. *ក្រុមជំនាញរបស់ ILO ចុះមកវាយតម្លៃសកម្មភាពប្រែក្លាយសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ឲ្យទៅជាសេដ្ឋកិច្ចក្នុងប្រព័ន្ធ ២០១៤-២០១៨.* ភ្នំពេញ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ថៃ សុម៉ារី និង ឡា ស៊ីឡាយ. ២០១៨. ការធ្វើចំណាកស្រុក. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ប៊ុន សេង និង អាន គឹម ស្រ៊. ២០១៧. ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ. សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

